# ព្រះរាជក្រម

នស/រកម/១២០៦/០៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើវិសោធនកម្មចំនួនបួននៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើ
## វិសោធនកម្មចំនួនបួននៃពិធីសារម៉ុងរ៉េអាល់ស្តីពី
## សារធាតុបំផ្លាញស្រទាប់អូហ្សូន

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើវិសោធនកម្មចំនួនបួននៃពិធីសារម៉ុងរ៉េអាល់ឆ្នាំ ១៩៨៧ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលធ្វើនៅ :

-ទីក្រុងឡុងដុង នាថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩០

-ទីក្រុងកូប៉ែនហាហ្គេន នាថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩២

-ទីក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៧ និង

-ទីក្រុងប៉េកាំង នាថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលើវិសោធនកម្មចំនួនបួននៃពិធីសារម៉ុងរ៉េអាល់នេះ ។

រាជធានីភ្នំពេញថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

៣៧.០៦១២.៥៣៦

ប្រមុខរដ្ឋស្តីទី

អគ្គលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខៈ ៤៨៤ច.ល

[illegible]

[illegible] ខែ ធ្នូ ឆ្នាំ២០០៦

[illegible]

ស៊ុន ចំនេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤២ នាគន.កបច

## សេចក្តីថ្លែងហេតុ

## នៃសេចក្តីព្រាងច្បាប់

## ស្តីពីការអនុម័តយល់ព្រមលើវិសោធនកម្មចំនួនបួននៃពិធីសារម៉ុងរ៉េអាល់

## ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

ក្នុងនាមប្រទេសជាសមាជិកនៃអនុសញ្ញាទីក្រុង វីយែន និងពិធីសារម៉ុងរ៉េអាល់ ចាប់ពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០១ ព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុង អនុសញ្ញា វីយែន និងពិធីសារម៉ុងរ៉េអាល់ដែលគោលបំណងសំខាន់គឺការលប់បំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន ។

ដើម្បីអនុវត្តអនុសញ្ញា វីយែន និងពិធីសារម៉ុងរ៉េអាល់ ឱ្យមានប្រសិទ្ធភាពក្នុងគោលបំណងកាត់បន្ថយ និងលប់បំបាត់នូវការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិ និងប្រតិភូមកពីប្រទេសជាច្រើនបានជួបប្រជុំគ្នា ដើម្បីអនុម័តលើវិសោធនកម្មចំនួន ៤ ធំៗ ហើយត្រូវបានអនុម័តដោយរដ្ឋាភិបាលមកពីប្រទេសជាច្រើន ។ វិសោធនកម្មទាំងនេះបានកែសម្រួល និងអនុមត័ដូចខាងក្រោម :

វិសោធនកម្ម ទីក្រុង ឡុងដុង បានអនុម័តក្នុងឆ្នាំ១៩៩០ នៅក្នុងកិច្ចប្រជុំភាគី នៃពិធីសារម៉ុងរ៉េអាល់លើកទី២ នៅទីក្រុង ឡុងដុង និងបានចូលជាធរមាននៅថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៩២ ។ វិសោធនកម្មនេះបានដាក់ចេញនូវពីរវិធានការត្រួតពិនិត្យទាំងការផលិត និងការប្រើប្រាស់ចំពោះសារធាតុថ្មីៗបីក្រុម គឺហាឡូហ្សែននៃសារធាតុ CFCs (សារធាតុនៅក្នុង ឧបសម្ព័ន្ធ B ក្រុម I) កាបូនតេត្រាក្លរ៉ាយ (ឧបសម្ព័ន្ធ B ក្រុម II ) និងម៉េទីលក្លរ៉ូហ្វម (methyl chloroform) ឬ1,1,1-trichloroethance (ឧបសម្ព័ន្ធ B ក្រុម III ) ។ វិធានការត្រួតពិនិត្យរួមមាន ការរឹតបន្តឹង ចំពោះការធ្វើពាណិជ្ជកម្មរវាងប្រទេសមិនមែនជាភាគី នៃពិធីសារម៉ុងរ៉េអាល់ផងដែរ ។

វិសោធនកម្មក៏បានដាក់ចេញនូវវិធានការចំពោះសារធាតុ HCFCs (សារធាតុនៅក្នុងឧបសម្ព័ន្ធ C ក្រុម I) ប៉ុន្តែតម្រូវឱ្យគ្រាន់តែរាយការណ៍ពីទិន្នន័យនៃការផលិត និងការប្រើប្រាស់តែប៉ុណ្ណោះសម្រាប់ឧបសម្ព័ន្ធ ដោយមិនបានដាក់នូវវិធានការត្រួតពិនិត្យឡើយ ។

ចំពោះយន្តការហិរញ្ញវត្ថុគឺត្រូវបានដាក់ចេញ (មាត្រា១០នៃពិធីសារ) សម្រាប់ផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍ ដូច្នេះប្រសិនបើប្រទេសកម្ពុជាមិនបានផ្តល់សច្ចាប័នលើវិសោធនកម្មនេះទេ គឺយើងមិនអាចទទួលបាននូវការឧបត្ថម្ភជាថវិកា និងបច្ចេកទេសពីអង្គការមូលនិធិពហុភាគីក្នុងការលុបបំបាត់សារធាតុបំផ្លាញស្រទាប់អូហ្សូនឡើយ ។ចំពោះការផ្តល់ថវិកាកន្លងមក គឺដោយសារការអនុគ្រោះ ពីព្រោះប្រទេសយើងបានចូលជាសមាជិកអនុសញ្ញានេះចុងក្រោយគេ ។

វិសោធនកម្មទីក្រុង កូប៉ែនហាហ្គេនបានអនុម័តនៅក្នុងឆ្នាំ ១៩៩២ នៅឯកិច្ចប្រជុំភាគី នៃពិធីសារម៉ុងរ៉េអាល់ លើកទី ៤ នាទីក្រុង កូប៉ែនហាហ្គេន និងបានចូលជាធរមាននៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៩២ ។ វិសោធនកម្មបានដាក់ចេញនូវវិធានការត្រួតពិនិត្យចំពោះការប្រើប្រាស់សារធាតុហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន Hydrochlorofluorocarbons (HCFCs) (សារធាតុនៅក្នុងឧបសម្ព័ន្ធ C ក្រុម I ) ។ វិសោធនកម្មក៏បានដាក់នូវវិធានការត្រួតពិនិត្យចំពោះការផលិត និងការប្រើប្រាស់សម្រាប់ក្រុមសារធាតុថ្មីពីរ គឺសារធាតុហាយដ្រូប្រូម៉ូភ្លុយអរ៉ូកាបូន Hydrobromofluorocarbon (HBFCs) (សារធាតុនៅក្នុងឧបសម្ព័ន្ធ C ក្រុម II ) និងម៉េទីលប្រូម៉ាយ (methyl bromide) (សារធាតុនៅក្នុងឧបសម្ព័ន្ធ E ក្រុម I) ។ សារធាតុហាយដ្រូប្រូម៉ូភ្លុយអរ៉ូកាបូន (HBFCs) និងម៉េទីលប្រូម៉ាយ (methyl bromide) ពុំមានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាទេ ។

វិសោធនកម្មទីក្រុងម៉ុងរ៉េអាល់ បានអនុម័តនៅក្នុងឆ្នាំ ១៩៩៧ នៅក្នុងកិច្ចប្រជុំភាគីពិធីសារម៉ុងរ៉េអាល់ លើកទី ៩ នាទីក្រុងម៉ុងរ៉េអាល់ និងបានចូលជាធរមាននៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។ វិសោធនកម្មនេះមិនបានដាក់ចេញវិធានការចំពោះសារធាតុថ្មីបន្ថែមទៀតទេ ។ ប៉ុន្តែវិសោធនកម្មបានដាក់ចេញនូវតម្រូវការប្រព័ន្ធអាជ្ញាប័ណ្ណ ដើម្បីអាចឱ្យភាគីជាសមាជិកធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងការធ្វើពាណិជ្ជកម្មនៃសារធាតុបំផ្លាញស្រទាប់អូហ្សូន ក្រោមពិធីសារម៉ុងរ៉េអាល់ ។ ចំពោះវិសោធនកម្មនេះ បើយើងមិនបានផ្តល់សច្ចាប័នទេនោះ យើងនឹងមិនអាចទទួលបានថវិកាក្នុងការរៀបចំច្បាប់ និងរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីគយ និងគម្រោងផ្សេងៗទៀតឡើយ តែផ្ទុយទៅវិញដោយប្រទេសកម្ពុជាយើងចូលជាសមាជិកក្រោយគេ អង្គការកម្មវិធីបរិស្ថានសហប្រជាជាតិមានការអនុគ្រោះដល់ប្រទេសកម្ពុជា ដោយផ្តល់ថវិកាក្នុងការរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់ អូហ្សូន ។

វិសោធនកម្មទីក្រុង ប៉េកាំង បានអនុម័តនៅក្នុងឆ្នាំ ១៩៩៧ នៅឯកិច្ចប្រជុំភាគីពិធីសារម៉ុងរ៉េអាល់លើកទី ៩ នាទីក្រុង ប៉េកាំង បានចូលជាធរមាននៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០២ ។ វិសោធនកម្មបានដាក់ចេញនូវវិធានការត្រួតពិនិត្យចំពោះការផលិតសារធាតុហាយដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន Hydrochlorofluorocarbons (HCFCs) តែមួយគត់ (សារធាតុនៅក្នុងឧបសម្ព័ន្ធ C ក្រុម I ) និងធ្វើការរឹតបន្តឹងចំពោះការផលិត និងការប្រើប្រាស់ និងធ្វើពាណិជ្ជកម្មសម្រាប់ក្រុមថ្មីនៃសារធាតុប្រូម៉ូក្លរ៉ូមេតាន bromochloromethane (BCM) (សារធាតុនៅក្នុងឧបសម្ព័ន្ធ C ក្រុម III ) ជាមួយប្រទេសមិនមែនជា

សមាជិកភាគីអនុសញ្ញាវីយែន និងពិធីសារម៉ុងរ៉េអាល់។ ចពោះវិសោធនកម្មនេះ ប្រសិនបើប្រទេសកម្ពុជា មិនបានផ្តល់សច្ចាប័នទេនោះគឺយើងមិនអាចនាំចូលនូវសារធាតុទាំងនេះបានឡើយ ។

ព្រះរាជាណាចក្រកម្ពុជាគួរតែត្រូវផ្តល់សច្ចាប័នលើវិសោធនកម្មទាំងបួននៃពិធីសារម៉ុងរ៉េអាល់ ពីព្រោះវាមានសារៈសំខាន់ក្នុងជំរុញការអនុវត្តអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន និងការអនុវត្តកម្មវិធីជាតិស្តីពីការគ្រប់គ្រងសារធាតុត្រជាក់នៅកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងនាមជាភាគីមួយនៃអនុសញ្ញាវីយែន និងពិធីសារម៉ុងរ៉េអាល់ ។

ពិនិត្យជារួម ការផ្តល់សច្ចាប័នលើវិសោធនកម្មនៃពិធីសារម៉ុងរ៉េអាល់នេះពុំនាំមកនូវផលវិបាកជាអវិជ្ជមានណាមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជាឡើយ។ ផ្ទុយទៅវិញវាបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល កាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងធនធានធម្មជាតិឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព ។

សេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើវិសោធនកម្មចំនួនបួននៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូននេះដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

សែន

# ពិធីសារម៉ុងរ៉េអាល់ស្តីពី
# សារធាតុដែលបំផ្លាញស្រទាប់ អូហ្សូន

បានកែសម្រួល និងបានធ្វើវិសោធនកម្ម ដោយកិច្ចប្រជុំរបស់ភាគីលើកទី ២
(ឡុងដុង ថ្ងៃទី២៧-២៩ មិថុនា ១៩៩០)
និងដោយកិច្ចប្រជុំរបស់ភាគីលើកទី ៤
(កូបេហាហ្គេន ថ្ងៃទី២៣-២៥ វិច្ឆិកា ១៩៩២)
និងបានកែសម្រួលបន្ថែម ដោយកិច្ចប្រជុំរបស់ភាគីលើកទី ៧
(វីយ៉ែន ថ្ងៃទី៥-៧ ធ្នូ ១៩៩៥)
និងបានកែសម្រួល និងបានធ្វើវិសោធនកម្មបន្ថែម ដោយកិច្ចប្រជុំរបស់ភាគីលើកទី ៩
(ម៉ុងរ៉េអាល់ ថ្ងៃទី១៥-១៧ កញ្ញា ១៩៩៧)
និងដោយកិច្ចប្រជុំរបស់ភាគីលើកទី ១១
(ប៉េកាំង ថ្ងៃទី២៩ វិច្ឆិកា-ថ្ងៃទី៣ ធ្នូ ១៩៩៩)

ភាគីនៃពិធីសារនេះ ជាភាគីនៃអនុសញ្ញា *Vienna* ដើម្បីការពារស្រទាប់ អូហ្សូន ។

ស្ថិតនៅក្រោមអនុសញ្ញានេះ ភាគីជាសមាជិកត្រូវយល់ដឹងអំពីការតព្វកិច្ចរបស់ខ្លួន គឺអនុវត្តវិធានការសមស្របសំដៅការពារសុខភាពមនុស្ស និងបរិស្ថានប្រឆាំងឥទ្ធិពលប៉ះពាល់ផ្សេងៗ បណ្តាលមកពីសកម្មភាពមនុស្សបង្កឱ្យមានការផ្លាស់ប្តូរ ឬមាននិន្នាការផ្លាស់ប្តូរស្រទាប់ អូហ្សូន ។

គួរយល់ដឹងចំពោះការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុពុល អាចបំផ្លាញស្រទាប់ អូហ្សូនក្នុងកម្រិតមួយ ដែលជះឥទ្ធិពលអាក្រក់ដល់សុខភាពមនុស្ស និងបរិស្ថាន ។

ការយល់ដឹងពីឥទ្ធិពលប៉ះពាល់យ៉ាងខ្លាំងក្លាដល់អាកាសធាតុ ដែលបណ្តាលមកពីការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុពុល ។

យល់ដឹងពីវិធានការការពារស្រទាប់ អូហ្សូន ប្រឆាំងនឹងសកម្មភាពបំផ្លាញផ្សេងៗ ដោយផ្អែកទៅលើចំណេះដឹងវិទ្យាសាស្ត្រ និងគិតគូរពីផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច ។

កំណត់ការពារស្រទាប់ អូហ្សូនដោយវិធានការបង្ការជាមុន សំដៅត្រួតពិនិត្យការបញ្ចេញសារធាតុពុលដែលបំផ្លាញស្រទាប់ អូហ្សូនទៅក្នុងបរិយាកាស ក៏ដូចជាកំណត់នូវទិសដៅខ្ពស់ក្នុងការបំបាត់ការបំផ្លាញស្រទាប់អូហ្សូនដោយផ្អែកទៅលើមូលដ្ឋាននៃការអភិវឌ្ឍន៍ផ្នែកចំណេះដឹងវិទ្យាសាស្ត្រ ត្រិះរិះពិចារណាទៅលើបច្ចេកទេសនិងសេដ្ឋកិច្ច និងគិតទៅ

ដល់តម្រូវការអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

ការទទួលស្គាល់ចំពោះសេចក្តីដែលមានចែងជាពិសេស គឺទាមទារតម្រូវទៅតាមសេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងខដែលមានអំពីធនធានហិរញ្ញវត្ថុបន្ថែមនិងសម្រាប់ប្រើប្រាស់ទៅលើបច្ចេកវិទ្យា ការគិតគូរប្រមើលមើលទៅលើបរិមាណថវិកាចាំបាច់ និងថវិកាវិពីងទុកសម្រាប់បង្កើនសមត្ថភាពតាមលក្ខណៈវិទ្យាសាស្ត្រ ដើម្បីកំណត់នូវបញ្ហាបំផ្លាញស្រទាប់ អូហ្សូន និងឥទ្ធិពលរបស់វា ។

កត់សម្គាល់ទៅលើវិធានការបង្ការសម្រាប់ត្រួតពិនិត្យការបញ្ចេញសារធាតុ Chlorofluorocarbons ដែលត្រូវបានអនុវត្តដោយថ្នាក់ជាតិ និងថ្នាក់តំបន់រួចទៅហើយ ។

ការត្រិះរិះពិចារណាទៅលើសារៈសំខាន់នៃការពង្រឹងកិច្ចសហការជាលក្ខណៈអន្តរជាតិ ក្នុងការស្រាវជ្រាវការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរបច្ចេកវិទ្យា ដែលទាក់ទងនឹងការត្រួតពិនិត្យ និងការកាត់បន្ថយការបញ្ចេញសារធាតុដែលបំផ្លាញស្រទាប់ អូហ្សូន ក៏ដូចជាការគិតទៅលើតម្រូវការផ្ទាល់របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

បានព្រមព្រៀងដូចតទៅ :

**<u>មាត្រា ១:</u> និយមន័យ**

សម្រាប់គោលបំណង នៃពិធីសារនេះ:

1. "អនុសញ្ញា" មានន័យថា អនុសញ្ញា *Vienna* ដើម្បីការពារស្រទាប់ អូហ្សូន ដែលបានអនុម័តនៅថ្ងៃទី ២២ ខែមីនា ឆ្នាំ១៩៨៥ ។

2. "ភាគី" មានន័យសំដៅទៅលើភាគីជាសមាជិករបស់ពិធីសារនេះ ។

3. "លេខាធិការដ្ឋាន" មានន័យសំដៅទៅលើលេខាធិការដ្ឋានរបស់អនុសញ្ញានេះ ។

4. "សារធាតុដែលត្រូវពិនិត្យ" គឺសំដៅទៅលើសារធាតុដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ **A** ឧបសម្ព័ន្ធ **B** ឧបសម្ព័ន្ធ **C** ឬឧបសម្ព័ន្ធ **E** របស់ពិធីសារនេះ ដែលស្ថិតនៅទោលតែឯងឬស្ថិតក្នុងស្ថានភាពជាល្បាយ ។ សារធាតុដែលត្រូវពិនិត្យមានទម្រង់ជាសារធាតុអ៊ីសូមែ លើកលែងតែបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធពាក់ព័ន្ធ ប៉ុន្តែមិនរាប់បញ្ចូលសារធាតុដែលត្រូវពិនិត្យឬល្បាយសារធាតុដែលជាផលិតផលត្រូវបានផលិតឡើង ក៏ដូចជាឧបករណ៍សំរាប់ផ្ទុកទំនិញដែលប្រើសំរាប់ដឹកជញ្ជូនឬស្តុកសារធាតុនោះ ។

5. "ផលិតផល" សំដៅទៅលើចំនួនផលិតផលសារធាតុដែលត្រូវពិនិត្យ ដក នឹងចំនួនសារធាតុដែលត្រូវបំផ្លាញចោលដោយបច្ចេកវិទ្យាដោយមានការឯកភាពពីភាគីជាសមាជិក និងដកជាមួយចំនួនសារធាតុសរុបដែលបានប្រើប្រាស់នៅក្នុងការផលិតសារធាតុគីមី ។ បរិមាណសារធាតុដែលត្រូវកែច្នៃ ឬត្រូវប្រើប្រាស់ឡើងវិញ ពុំចាត់ទុកជាផលិតផលទេ ។

6. "ការប្រើប្រាស់" គឺសំដៅទៅលើផលិតផលដែលផលិតបានបូកនឹងបរិមាណសារធាតុដែលត្រូវពិនិត្យដែលបាននាំចូល និងដកបរិមាណសារធាតុដែលត្រូវពិនិត្យដែលបាននាំចេញ ។

7. "កំរិតប៉ាន់ស្មាន" នៃផលិតផល ការនាំចូល ការនាំចេញ និងការប្រើប្រាស់ គឺសំដៅទៅលើកំរិតមួយ ដែលបានកំណត់ ដោយផ្អែកទៅតាមមាត្រា ៣ ។

8. "ការបង្កលក្ខណៈគ្រប់គ្រាន់និងងាយស្រួលដល់វិស័យឧស្សាហកម្ម" *(Industrial rationalization)* គឺសំដៅទៅលើការផ្លាស់ប្តូរកំរិតប៉ាន់ស្មានការផលិតក្នុងចំនួនតិចឬច្រើនពីភាគីមួយទៅភាគីមួយទៀត ដែលជាគោលដៅនៃការសម្រេចសេដ្ឋកិច្ចសំបូររុងរឿង ឬដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយការផ្គត់ផ្គង់ទៅតាមការគ្រោងទុកតាមរយៈលទ្ធផលនៃការបិទរោងចក្រ ។

**មាត្រាទី ២ : វិធានការត្រួតពិនិត្យ**

1. ភ្ជាប់ក្នុងមាត្រា ២A
2. ជំនួសដោយមាត្រា ២B
3. ជំនួសដោយមាត្រា ២A
4. ជំនួសដោយមាត្រា ២A

5. ចំពោះរយៈពេលត្រួតពិនិត្យម្តងឬច្រើនដង ភាគីទាំងឡាយអាចធ្វើការផ្ទេរផលិតផលក្នុងកំរិតប៉ាន់ស្មាន ទៅអោយភាគីដទៃ ដូចមានចែងនៅក្នុងមាត្រា ២A ទៅ ២F និង មាត្រា ២H ថា កំរិតប៉ាន់ស្មានផលិតផលចំពោះនៃសារធាតុដែលត្រូវពិនិត្យរបស់ភាគីពាក់ព័ន្ធ មិនត្រូវលើសពីកំរិតនៃការផលិតដែលមានចែងនៅក្នុងមាត្រាខាងលើ ។ ការផ្ទេរផលិតផលនេះ នឹងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានតាមរយៈភាគីពាក់ព័ន្ធនីមួយៗ ដោយលើកឡើងពីល័ក្ខខ័ណ្ឌផ្ទេរ និងរយៈពេលអនុវត្ត ។

5. bis. ចំពោះរយៈពេលត្រួតពិនិត្យម្តងឬច្រើនដង ភាគីដែលមិនអនុវត្តតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ អាចផ្ទេរផលិតផល ដែលមានបរិមាណស្ថិតក្នុងផ្នែកមួយនៃកំរិតប៉ាន់ស្មានដូចមានចែងនៅក្នុងមាត្រា ២F ថាកំរិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A ដែលត្រូវបញ្ជូនទៅអោយភាគីដទៃមិនត្រូវលើស ០.២៥ គីឡូក្រាម សំរាប់មនុស្សម្នាក់ក្នុងឆ្នាំ ១៩៨៩ ហើយកំរិតប៉ាន់ស្មានការប្រើប្រាស់សារធាតុល្បាយដែលត្រូវពិនិត្យរបស់ភាគីពាក់ព័ន្ធ មិនត្រូវលើសកំរិតកំណត់លើការប្រើប្រាស់ដូចមានចែងក្នុងមាត្រា ២F ។ ភាគីពាក់ព័ន្ធនីមួយៗ ត្រូវផ្តល់ពត៌មានទៅលេខាធិការដ្ឋានចំពោះការផ្ទេរសារធាតុប្រើប្រាស់ ដោយរៀបរាប់ពីល័ក្ខខ័ណ្ឌនៃការដឹកជញ្ជូន និងពេលវេលា នៃការអនុវត្តន៍ ។

6. ភាគីទាំងឡាយដែលមិនបានអនុវត្តតាមមាត្រា ៥ ដោយសារគ្រឿងបរិក្ខារសម្រាប់ផលិតសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A និង B កំពុងដំណើរការសាងសង់ឬកំពុងជាប់កិច្ចព្រមព្រៀង ដែលបានធ្វើឡើងមុនថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៨៧ និងដែលបានអនុញ្ញាតដោយច្បាប់មុនថ្ងៃទី ១ ខែមករា ឆ្នាំ១៩៨៧ អាចបន្ថែមគ្រឿងបរិក្ខាទៅលើផលិតផល ឆ្នាំ១៩៨៦ របស់ខ្លួន សម្រាប់គោលបំណងនៃការកំណត់កម្រិតប៉ាន់ស្មានការផលិតសម្រាប់ឆ្នាំ១៩៨៦ ដែលបានចងថា គ្រឿងបរិក្ខាទាំងនេះត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩០ ហើយផលិតផលនេះមិនត្រូវលើស ០.៥ គីឡូក្រាម នៃកម្រិតប៉ាន់ស្មាន លើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យសម្រាប់មនុស្សម្នាក់ៗទេ ។

7. ការផ្ទេរផលិតផលទាក់ទងនឹងកថាខ័ណ្ឌ ៥ ឬការបន្ថែមផលិតផលទាក់ទងនឹងកថាខ័ណ្ឌ ៦ ត្រូវជូនពត៌មានទៅលេខាធិការដ្ឋាន អោយបានមុនពេលអនុវត្តការផ្ទេរ ឬការបន្ថែមផលិតផល ។

8. (a) ដូចមានបញ្ជាក់ក្នុងមាត្រា ១ (៦) នៃអនុសញ្ញា ភាគីទាំងឡាយដែលជាប្រទេសសមាជិកអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចព្រមព្រៀងចូលរួមបំពេញកាតព្វកិច្ចលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ដូចមានចែងក្នុងមាត្រានេះ និងមាត្រា ២ A រហូតដល់មាត្រា ២ I ស្តីពីល័ក្ខខ័ណ្ឌនៃកម្រិតប៉ាន់ស្មានលើការប្រើប្រាស់រួម មិនត្រូវលើសកំរិតដែលតម្រូវដោយមាត្រានេះ និងមាត្រា ២ A រហូតដល់មាត្រា ២ I ។

(b) ភាគីនៃកិច្ចព្រមព្រៀង ត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអំពីល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងអោយបានមុនកាលបរិច្ឆេទនៃការកាត់បន្ថយការប្រើប្រាស់ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀង ។

(c) កិច្ចព្រមព្រៀងនឹងមានប្រសិទ្ធិភាព ប្រសិនបើប្រទេសជាសមាជិកអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ និង អង្គការពាក់ព័ន្ធដែលជាសមាជិករបស់ពិធីសារជូនពត៌មានទៅលេខាធិការដ្ឋាន អំពីការអនុវត្តន៍របស់គេ ។

9. a) ផ្អែកទៅតាមការវាយតម្លៃដែលធ្វើឡើងដោយអនុលោមទៅតាមមាត្រា ៦ ភាគីអាចធ្វើសេចក្តីសម្រេច :

i. ការកែតម្រូវទៅលើសក្តានុពលនៃការបំផ្លាញស្រទាប់ អូហ្សូនដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ A ឧបសម្ព័ន្ធ B ឧបសម្ព័ន្ធ C និង ឧបសម្ព័ន E នឹងត្រូវធ្វើឡើង បើដូច្នោះ តើបញ្ហាអ្វីខ្លះគួរកែតម្រូវ ។

ii. ការកែតម្រូវនិងការកាត់បន្ថយការផលិតឬការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ គួរតែត្រូវមានការទទួលខុសត្រូវ បើដូច្នោះ តើការកែតម្រូវនិងការកាត់បន្ថយគួរមានទំហំ ចំនួននិងរយៈពេលប៉ុន្មាន ។

b) សំណើសុំកែតម្រូវ ត្រូវផ្សព្វផ្សាយជាពត៌មានទៅភាគីទាំងឡាយតាមរយៈលេខាធិការដ្ឋាន ដែលយ៉ាងហោចណាស់ អោយបានរយៈពេល ៦ ខែ មុនកិច្ចប្រជុំនៃភាគីជាសមាជិក ដើម្បីស្នើសុំការអនុម័ត ។

c) ក្នុងការធ្វើសេចក្តីសម្រេចនេះ ភាគីជាសមាជិកត្រូវប្រឹងប្រែងកំណត់នូវកិច្ចព្រមព្រៀងដោយការស្របមតិគ្នា។ ប្រសិនបើការប្រឹងប្រែងរកការព្រមព្រៀងគ្នាត្រូវធ្វើឡើងដោយអស់សមត្ថភាព ហើយទីបញ្ចប់ពុំមានការឯកភាពគ្នាសេចក្តីសម្រេចនេះនឹងត្រូវដោះស្រាយជាលើកចុងក្រោយ ដោយអនុម័តតាមការបោះឆ្នោតយកសម្លេង ២ ភាគ ៣ នៃវត្តមានភាគីដែលចូលរួមប្រជុំ និងការបោះឆ្នោតតំណាងមតិភាគច្រើនទៅលើការអនុវត្តន៍របស់ភាគីតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ និងការបោះឆ្នោតតំណាងមតិភាគច្រើនដែលមិនអនុវត្តតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ នេះ ។

d) សេចក្តីសម្រេចនេះ នឹងត្រូវចងក្រងសម្រាប់គ្រប់ភាគីបន្ទាប់ពីទំនាក់ទំនងទៅភាគីដោយតម្កល់ទុក ។ ម្យ៉ាងវិញទៀតការផ្តល់សេចក្តីសម្រេច និងចូលជាធរមានបន្ទាប់ពី ៦ ខែចាប់ពីថ្ងៃផ្សព្វផ្សាយ។

10. ផ្អែកទៅតាមការវាយតម្លៃដែលធ្វើឡើងតាមមាត្រា ៦ នៃពិធីសារនេះ និងយោងទៅតាមនិតិវិធីដែលបានចែងក្នុងមាត្រា ៩ នៃអនុសញ្ញា ភាគីទាំងឡាយអាចធ្វើសេចក្តីសម្រេច :

a) ថាតើសារធាតុណា ត្រូវបន្ថែមឬដកចេញពីឧបសម្ព័ន្ធនៃពិធីសារនេះ

b) យន្តការ ទំហំនិងពេលវេលា នៃវិធានការត្រួតពិនិត្យ នឹងត្រូវអនុវត្តចំពោះសារធាតុទាំងនោះ

11. ទោះបីជាល័ក្ខខ័ណ្ឌមានចែងនៅក្នុងមាត្រានេះ និង មាត្រា ២A រហូតដល់ មាត្រា ២I ក៏ដោយ ភាគីទាំងឡាយអាចប្រកាន់នូវវិធានការតឹងរឹងជាងល័ក្ខខ័ណ្ឌដែលតម្រូវឱ្យអនុវត្តដោយមាត្រាទាំងនេះ ។

**មាត្រាទី ២A : CFCS**

1. ក្នុងអំឡុងពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ដែលពិធីសារនេះត្រូវចូលជាធរមានរហូតដល់រយៈពេល ៧ ខែ និងរយៈពេល ១២ ខែបន្ត ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតនៅក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A មិនត្រូវលើសកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ១៩៨៦ ។ នៅពេលបញ្ចប់រយៈពេលដដែលនេះ សមាជិកនីមួយៗដែលបានផលិតសារធាតុទាំងនេះតិចឬច្រើន ត្រូវធានាឱ្យបាននូវកម្រិតសារធាតុប៉ាន់ស្មានមិនត្រូវលើសពីកម្រិតផលិតផលប៉ាន់ស្មាននាឆ្នាំ១៩៨៦ ឬអាចលើកលែងបាន ចំពោះកម្រិតផលិតផលប៉ាន់ស្មានដែលកើនឡើងតិចជាង ១០% ។ កំណើននេះត្រូវបានអនុញ្ញាតទៅតាមតម្រូវការជាមូលដ្ឋានរបស់ប្រទេសជាសមាជិកដែលអនុវត្តតាមមាត្រា ៥ និងសម្រាប់គោលបំណង នៃការបង្កលក្ខណៈគ្រប់គ្រាន់ និងងាយស្រួលដល់វិស័យឧស្សាហកម្ម ។

2. ចាប់ពីថ្ងៃទី ១ ខែកក្កដា ឆ្នាំ១៩៩១ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩២ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់និងការផលិតសារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A មិនត្រូវលើសពី ១៥០ % នៃកម្រិតប៉ាន់ស្មានលើការប្រើប្រាស់និងការផលិតសារធាតុដែលត្រូវពិនិត្យក្នុងឆ្នាំ ១៩៨៦ ហើយប្រការនេះ នឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៣ រីឯរយៈពេលត្រួតពិនិត្យ នឹងចាប់ផ្តើមពីថ្ងៃទី ១ ខែមករា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។

3. ក្នុងរយៈពេល១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៤ និង រយៈពេល ១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យប្រចាំឆ្នាំ ស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A មិនត្រូវលើសពី ២៥ % នៃកម្រិតប៉ាន់ស្មានលើការផលិតក្នុងឆ្នាំ ១៩៨៦ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តន៍របស់ភាគីជាសមាជិកតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់ នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៨៦ រហូតដល់ ១០% ។

4. ក្នុងរយៈពេល ១២ ខែដំបូងចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦ និង រយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A មិនត្រូវលើសពីកំរិតសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុទាំងនេះតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើសកម្រិតសូន្យ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ១ នៃមាត្រា ៥ នោះកម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃតម្រិតការផលិតបរិមាណដូចគ្នាទៅនឹងការផលិតមធ្យមប្រចាំឆ្នាំនូវសារធាតុត្រូវពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធ A សម្រាប់តម្រូវការជាមូលដ្ឋានក្នុងកំឡុងឆ្នាំ ១៩៩៥ ទៅ ១៩៩៧ ។ កថាខ័ណ្ឌនេះ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវចំពោះ

ទំហំសម្រាប់ធ្វើជាគោល ដែលភាគីសម្រេចអនុញ្ញាតឱ្យកម្រិតការផលិតឬការប្រើប្រាស់ឱ្យមានលក្ខណៈសមស្រប ទៅនឹងការប្រើប្រាស់ដែលបានព្រមព្រៀងដោយពួកគេ ។

5. ក្នុងរយៈពេល ១២ ខែដំបូងចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៣ និងរយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្មនៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៥ មិនឱ្យលើសពី ៨០ % ក្នុងមួយឆ្នាំជាមធ្យម នៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសំរាប់ឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៧ ទាំងស្រុង។

6. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្មនៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A ដោយផ្អែកលើតម្រូវការក្នុងស្រុកនៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៥ មិនអោយលើសពី ៥០ % ក្នុងមួយឆ្នាំជាមធ្យម នៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសំរាប់ឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៧ ទាំងស្រុង ។

7. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៧ និងរយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្ម នៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៥ មិនអោយលើសពី ១៥ % ក្នុងមួយឆ្នាំជាមធ្យម នៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសំរាប់ឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៧ ទាំងស្រុង។

8. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១០ និង រយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្ម នៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៥ មិនអោយលើសពី 0 ។

9. ក្នុងគោលបំណងនៃការគណនាតម្រូវការក្នុងស្រុកក្រោមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។ ការគណនាមធ្យមភាគផលិតកម្មប្រចាំឆ្នាំដោយភាគីមួយរួមមានសិទ្ធិទទួលការផលិតដែលបានផ្ទេរអនុលោមទៅតាមកថាខ័ណ្ឌ ៥ នៃមាត្រា ២ និងលើកលែងសិទ្ធិទទួលការផលិតដោយអនុលោមទៅតាមកថាខ័ណ្ឌ ៥ នៃមាត្រា ២ ។

## មាត្រា ២B : HALONS

1. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩២ និងរយៈពេល ១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុមទី ២ នៃឧបសម្ព័ន្ធ A មិនត្រូវលើសពីកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៨៦ ។ ការផលិតសារធាតុតិចឬច្រើនក្នុងរយៈពេលដូចគ្នារបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើសកម្រិតប៉ាន់ស្មានលើការផលិតនាឆ្នាំ១៩៨៦ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុង នៃការអនុវត្តន៍របស់ភាគីជាសមាជិកដែលអនុវត្តតាម

កថាខ័ណ្ឌ ១ នៃមាត្រា ៥ នោះកម្រិតប៉ាន់ស្មានលើការផលិតអាចលើសការកំណត់នៃកម្រិតការផលិតឆ្នាំ ១៩៨៦ រហូតដល់ ១០ % ។

2. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល ១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ A មិនត្រូវលើសពីកំរិតសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុទាំងនេះតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាអោយបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើសកំរិតសូន្យ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុកនៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ១ នៃមាត្រា ៥ នោះកម្រិតប៉ាន់ស្មានលើការផលិតរហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ២០០២ អាចលើសការកំណត់ នៃកំរិតការផលិតឆ្នាំ ១៩៨៦ រហូតដល់ ១៥ បន្ទាប់មកអាចលើសកំរិតស្មើ និងកម្រិតមធ្យមប្រចាំឆ្នាំនៃការផលិតនូវសារធាតុត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ A ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុកសម្រាប់ឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៧ ទាំងស្រុង ។ កថាខ័ណ្ឌនេះមានវិសាលភាពចំពោះទំហំសម្រាប់ធ្វើជាគោល ដែលភាគីដែលសម្រេចអនុញ្ញាតឱ្យកម្រិតនៃការផលិត ឬការប្រើប្រាសដែលចាំបាច់សមស្របទៅនឹងការប្រើប្រាស់ដែលបានព្រមព្រៀងដោយពួកគេ ។

3. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ និង រយៈពេល ១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្មនៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ A ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៥ មិនឱ្យលើសពី ៥០ % នៃកម្រិតមធ្យមប្រចាំឆ្នាំ នៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុក សម្រាប់ឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៧ ទាំងស្រុង ។

4. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១០ និង រយៈពេល ១២ ខែបន្តបន្ទាប់ ភាគីនិមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្ម នៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ A ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃ មាត្រា ៥ មិនឱ្យលើសពី ០ ។

## <u>មាត្រា ២C :</u> OTHER FULLY HALOGENATED CFCs

1. ក្នុងរយៈពេល ១២ ខែ ដែលចាប់ផ្តើមពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៣ ភាគីនីមួយៗ ត្រូវធានាឱ្យបានជាប្រចាំនូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុមទី ២ នៃឧបសម្ព័ន្ធ B មិនត្រូវលើស ៨០ % ពីកំរិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៨៩ ទេ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតមិនត្រូវលើស ៨០ % នៃកំរិតប៉ាន់ស្មានលើការផលិតសារធាតុនា ឆ្នាំ ១៩៨៩ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកដែលអនុវត្តតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ នោះកំរិតប៉ាន់ស្មានលើការផលិតអាចលើសការកំណត់នៃកម្រិតការផលិត ឆ្នាំ ១៩៨៩ រហូតដល់ ១០% ។

2. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល ១២ ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យប្រចាំឆ្នាំ ស្ថិតក្នុងក្រុម ១ នៃ ឧបសម្ព័ន្ធ B មិនត្រូវលើសពី ២៥ % នៃកម្រិតប៉ាន់ស្មានលើការផលិតក្នុងឆ្នាំ ១៩៨៩ ។ ក្នុងរយៈពេលដដែលនេះដែរការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើសកម្រិត ២៥ % នៃកម្រិតប៉ាន់ស្មានលើការផលិតសារធាតុនាឆ្នាំ ១៩៨៩ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុកនៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៨៩ រហូតដល់ ១០ % ។

3. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៦ និង រយៈពេល១២ ខែ បន្តបន្ទាប់ ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ B មិនត្រូវលើសពីកម្រិតសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើសកម្រិតសូន្យ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កំរិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកម្រិតប៉ាន់ស្មានការផលិតរហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៣កំណត់មិនឱ្យលើសពី ១៥ % នៃការផលិតឆ្នាំ ១៩៨៩ ។ បន្ទាប់មកការលើសបរិមាណចំនួនកំនត់ស្មើ ៨០ % នៃកម្រិតមធ្យមប្រចាំឆ្នាំនៃការផលិតសារធាតុ ដែលត្រូវពិនិត្យនៅក្នុងក្រុម ១ នៃឧបសម្ព័ន្ធ B សម្រាប់លើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០០០ ទាំងស្រុង ។ កថាខ័ណ្ឌនេះ នឹងធ្វើការកម្រិតនូវដែនដែលភាគីធ្វើការសម្រេចក្នុងការអនុញ្ញាតកម្រិតផលិតកម្ម ឬការប្រើប្រាស់ជាចាំបាច់។

4. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៧ និង រយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្មនៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ B ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗជាសមាជិកក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៥ មិនឱ្យលើសពី ១៥ % ក្នុងមួយឆ្នាំជាមធ្យម នៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ ១៩៩៨ រហូតដល់ឆ្នាំ ២០០០- ទាំងស្រុង។

5. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១០ និងរយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតកម្ម នៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ B ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ១ នៃ មាត្រា ៥ មិនឱ្យលើសពី 0 ។

## <u>មាត្រា ២D :</u> **កាបូនតេត្រាក្លរ៉ាយ (Carbon Tetrachloride)**

1. ក្នុងរយៈពេល ១២ ខែ ដែលចាប់ផ្តើមពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៥ ភាគីនិមួយៗ ត្រូវធានាឱ្យបានជាប្រចាំនូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុមទី ២ នៃឧបសម្ព័ន្ធ B មិនត្រូវលើស ១៥ % ពីកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ១៩៨៩ ទេ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគី

នីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើស ១៥ % នៃកម្រិតប៉ាន់ស្មានលើការផលិតសារធាតុនាឆ្នាំ ១៩៨៩ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកដែលអនុវត្តតាមកថាខ័ណ្ឌ១ នៃមាត្រា ៥ នោះកម្រិតប៉ាន់ស្មានលើការផលិតអាចលើសការកំណត់ នៃកម្រិតការផលិតឆ្នាំ ១៩៨៩ រហូតដល់ ១០% ។

2. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល ១២ ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ B មិនត្រូវលើសពីកម្រិតសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើសកម្រិតសូន្យ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតំរូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កំរិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកំរិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៨៩ រហូតដល់ ១៥ % ។ កថាខ័ណ្ឌនេះ មានវិសាលភាពសំរាប់ភាគីសម្រេចអនុញ្ញាតឱ្យកម្រិតការផលិត ឬការប្រើប្រាស់ដែលត្រូវការជាចាំបាច់ដូចដែលបានព្រមព្រៀងដោយពួកគេ ។

## <u>មាត្រា ២E :</u> មេទីលក្លរ៉ូហ្វម (1,1,1-Trichlorethane)

1. ក្នុងរយៈពេល ១២ ខែ ដែលចាប់ផ្តើមពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៣ ភាគីនីមួយៗត្រូវធានាឱ្យបានជាប្រចាំនូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុមទី ៣ នៃឧបសម្ព័ន្ធ B មិនត្រូវលើសកំរិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៨៩ ទេ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុជាប្រចាំ មិនត្រូវលើសនៃកម្រិតប៉ាន់ស្មានលើការផលិតសារធាតុនាឆ្នាំ ១៩៨៩ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តន៍របស់ភាគីជាសមាជិកដែលអនុវត្តតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ នោះកម្រិតប៉ាន់ស្មានលើការផលិត អាចលើសការកំណត់ នៃកម្រិតការផលិតឆ្នាំ ១៩៨៩ រហូតដល់ ១០% ។

2. ក្នុងរយៈពេល ១២ ខែដំបូងចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល ១២ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានជាប្រចាំ លើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ៣ នៃឧបសម្ព័ន្ធ B មិនត្រូវលើសពី ៥០ % ពីកំរិតប៉ាន់ស្មានលើការប្រើប្រាស់ក្នុងឆ្នាំ ១៩៨៩ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុជាប្រចាំមិនត្រូវលើសកំរិត ៥០ % នៃកម្រិតប៉ាន់ស្មានលើការផលិតសារធាតុនាឆ្នាំ ១៩៨៩ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់ នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៨៩ រហូតដល់ ១០% ។

3. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦ និងរយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងក្រុម ៣ នៃឧបសម្ព័ន្ធ B មិនត្រូវលើសពីកម្រិតសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិត

ប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើសកម្រិតសូន្យ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកក្រោមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៨៩ រហូតដល់ ១៥ % ។ កថាខ័ណ្ឌនេះ មានវិសាលភាពចំពោះភាគីសម្រេចអនុញ្ញាតឱ្យកម្រិត នៃការផលិតឬការប្រើប្រាស់ចាំបាច់ដែលបានព្រមព្រៀងដោយពួកគេ ។

## **មាត្រា 2F : HYDROCHLOROFLUOROCARBONS**

**1.** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៦ និង រយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកម្រិតដូចខាងក្រោម÷

**a)** ២.៨ % នៃកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A នាឆ្នាំ ១៩៨៩ ។

**b)**កម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C នាឆ្នាំ ១៩៨៩ ។

**2.** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៤ និង រយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកម្រិត ៦៥ % នៃចំនួនដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

**3.** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១០ និងរយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ានស្មានជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកំរិត ៦៥ % នៃចំនួនដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

**4.** ក្នុងរយៈពេល ១២ ខែដំបូងចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៥ និងរយៈពេល ១២ ខែបន្តបន្ទាប់ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកំរិត ១០ % នៃចំនួនដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

**5។** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០២០ និងរយៈពេល ១២ ខែ បន្តបន្ទាប់ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកម្រិត ០.៥ 5 នៃចំនួនដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់នេះគឺកម្រិតសម្រាប់តែសេវាកម្មម៉ាស៊ីនត្រជាក់ និងឧបករណ៍ត្រជាក់ដែលមានស្រាប់តែប៉ុណ្ណោះ ។

**6.** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០៣០ និងរយៈពេល ១២ ខែបន្តបន្ទាប់ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកម្រិតសូន្យ ។

**7.** ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៦ ភាគីនីមួយៗត្រូវធានាឱ្យបាននូវ÷

**a)** ការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C ត្រូវបានកំណត់ទៅលើសារធាតុ

ដែលត្រូវប្រើប្រាស់ជំនួសដោយពុំមានលក្ខណៈសមស្របទៅតាមទ្រឹស្តីបរិស្ថានឬបច្ចេកទេស ។

b) ការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C មិនត្រូវឱ្យប្រាស់ចាកពីការអនុវត្តន៍បច្ចុប្បន្នទៅលើសារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធ A ឧបសម្ព័ន្ធ B និង ឧបសម្ព័ន្ធ C លើកលែងតែក្នុងករណីចាំបាច់ដើម្បីការពារជីវិត និង សុខភាពមនុស្ស ។

c) សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C ត្រូវបានជ្រើសរើសសម្រាប់ប្រើប្រាស់ក្នុងលក្ខណៈកាត់បន្ថយការបំផ្លាញស្រទាប់ អូហ្សូន រួមទាំងការគិតគូរពីបញ្ហាបរិស្ថាន សុវត្ថិភាព និង សេដ្ឋកិច្ច ។

8. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៤ និងរយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗដែលកំពុងផលិតសារធាតុមួយ ឬច្រើន ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានជាប្រចាំលើការប្រើប្រាស់សារធាតុ ដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកម្រិតមធ្យមភាគប្រចាំឆ្នាំនៃ :

a) កម្រិតចំនួនប្រើប្រាស់សរុបប្រចាំឆ្នាំក្នុងឆ្នាំ ១៩៨៩ នៃសារធាតុត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C និងក្នុងកម្រិតប៉ាន់ស្មាន ២.៨ % នៃកម្រិតប្រើប្រាស់ក្នុងឆ្នាំ ១៩៨៩ នៃសារធាតុត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A និង

b) កម្រិតចំនួនផលិតសរុបប្រចាំឆ្នាំក្នុងឆ្នាំ ១៩៨៩ នៃសារធាតុត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C និងក្នុងកម្រិតប៉ាន់ស្មាន ២.៨ % នៃកម្រិតប្រើប្រាស់ក្នុងឆ្នាំ ១៩៨៩ នៃសារធាតុត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ A ។

ម្យ៉ាងវិញទៀត ដើម្បីបំពេញតម្រូវការក្នុងស្រុក នៃប្រតិបត្តិការរបស់ភាគីក្រោមកថាខណ្ឌ ១ នៃមាត្រា ៥ ។ ការប៉ាន់ស្មានកម្រិតផលិតកម្មមិនឱ្យលើសពីចំនួនកំនត់ ១៥ % នៃកម្រិតផលិតនៃសារធាតុត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃ ឧបសម្ព័ន្ធ A ដូចបានបង្ហាញខាងលើ ។

### មាត្រា 2G : Hydrobromofluorocarbons

ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦ និងរយៈពេល ១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងក្រុម ២ នៃឧបសម្ព័ន្ធ C មិនត្រូវលើសពីកម្រិតសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើសកម្រិតសូន្យ ។ កថាខណ្ឌនេះ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវចំពោះទំហំសម្រាប់ធ្វើជាគោល ដែលភាគីសម្រេចអនុញ្ញាតឱ្យកម្រិត នៃការផលិតឬការប្រើប្រាស់មានលក្ខណៈសមស្របទៅនឹងការប្រើប្រាស់ដែលបានព្រមព្រៀងដោយពួកគេ ។

### មាត្រា 2H : មេទីលប្រូម៉ាយ (Methyl Bromide)

1. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៥ និង រយៈពេល ១២ ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធ E មិនត្រូវលើស

ពីកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៩១ ។ ក្នុងរយៈពេលដដែលនេះដែរការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ មិនត្រូវលើសកម្រិតប៉ាន់ស្មានលើការផលិតសារធាតុក្នុងឆ្នាំ ១៩៩១ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តន៍របស់ភាគីជាសមាជិកតាមកថាខ័ណ្ឌ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកំរិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៩១ រហូតដល់ ១០ % ។

2. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៩ និង រយៈពេល ១២ ខែ បន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធ E មិនត្រូវលើស ៧៥ % ពីកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៩១ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើស ៧៥ % កំរិតប៉ាន់ស្មានលើការផលិតសារធាតុក្នុងឆ្នាំ ១៩៩១ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កំរិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកំរិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៩១ រហូតដល់ ១០ % ។

3. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០១ និង រយៈពេល ១២ ខែ បន្តបន្ទាប់ ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធ A មិនត្រូវលើស ៥០ % ពីកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៩១ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើស ៥០ % កំរិតប៉ាន់ស្មានលើការផលិតសារធាតុក្នុងឆ្នាំ ១៩៩១ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៩១ រហូតដល់ ១០ % ។

4. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៣ និងរយៈពេល ១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធ E មិនត្រូវលើស ៣០ % ពីកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ១៩៩១ ។ ក្នុងរយៈពេលដដែលនេះដែរការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើស ៣០ % កម្រិតប៉ាន់ស្មានលើការផលិតសារធាតុក្នុងឆ្នាំ ១៩៩១ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ កម្រិតប៉ាន់ស្មានការផលិតអាចលើសការកំណត់នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៩១ រហូតដល់ ១០ % ។

5. ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ និង រយៈពេល ១២ ខែ បន្តបន្ទាប់ ភាគី

នីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធ E មិនត្រូវលើសសូន្យ ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើសសូន្យ ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តន៍របស់ភាគីជាសមាជិកតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ ក៏កិតប៉ាន់ស្មានការផលិតរហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០២ អាចលើសការកំណត់នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ ១៩៩១ រហូតដល់ ១៥ % ។ បន្ទាប់មកទៀតវាអាចលើសបរិមាណមធ្យមភាគប្រចាំឆ្នាំនៃការផលិតសារធាតុត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ E សម្រាប់តម្រូវការក្នុង ស្រុកក្នុងកំឡុងឆ្នាំ ១៩៩៥ ដល់ ១៩៩៨ ទាំងស្រុង ។ ក្នុងកថាខ័ណ្ឌនេះនឹងជួយការបន្ថយដល់ភាគីក្នុងការអនុញ្ញាតផលិត ឬ ប្រើប្រាស់ដែលជាការចាំបាច់ដែលបានព្រមព្រៀងដោយពួកគេ។

**5 *bis.*** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតផលនៃសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ E ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខ័ណ្ឌ ១ នៃ មាត្រា ៥ មិនឱ្យលើសពី ៨០ % ធៀបទៅកម្រិតមធ្យមប្រចាំឆ្នាំ នៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ ១៩៩៥ រហូតដល់ឆ្នាំ ១៩៩៨ ទាំងស្រុង។

**5 *ter.*** ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៥ និង រយៈពេល១២ ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្ម នៃសារធាតុដែលត្រូវពិនិត្យក្នុង ឧបសម្ព័ន្ធ E ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗ នៅក្នុងកថាខ័ណ្ឌ ១ នៃ មាត្រា ៥ មិនឱ្យលើសពីសូន្យ ។

**6.** ការប៉ាន់ស្មានកម្រិតប្រើប្រាស់ និងផលិតកម្មក្រោមមាត្រានេះមិនរួមបញ្ចូលបរិមាណប្រើប្រាស់ដោយភាគី សម្រាប់បំបាត់កត្តាចង្រៃ និងក្នុងទម្រង់រៀបចំការដឹកជញ្ជូន។

## <u>មាត្រា ២ I:</u> ប្រូម៉ូក្លរ៉ូមេតាន (Bromochloromethane)

ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០២ និងរយៈពេល១២ ខែបន្តបន្ទាប់ភាគី នីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើផលិតកម្ម និងការប្រើប្រាស់នៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម 3 នៃឧបសម្ព័ន្ធ C មិនឱ្យលើសពីសូន្យ ។ ក្នុងកថាខ័ណ្ឌនេះ និងជួយដល់ភាគីក្នុងការអនុញ្ញាតផលិត ឬប្រើប្រាស់ដែលជាការចាំបាច់ ដែលបានព្រមព្រៀងដោយពួកគេ។

## <u>មាត្រា ៣ :</u> ការគណនាកំរិតត្រួតពិនិត្យ

ដើម្បីអនុវត្តគោលបំណងមាត្រា ២ មាត្រា ២A ទៅ ២I និងមាត្រា ៥ ភាគីនីមួយៗ ត្រូវកំណត់កម្រិតប៉ាន់ស្មានចំពោះសារធាតុនៅក្នុងឧបសម្ព័ន្ធ A ឧបសម្ព័ន្ធ B ឧបសម្ព័ន្ធ C ឬ ឧបសម្ព័ន្ធ E :

a) ការផលិតអាស្រ័យដោយ:

(i) គុណបរិមាណផលិតផលសារធាតុដែលត្រូវពិនិត្យប្រចាំឆ្នាំ និងឥទ្ធិពលនៃការបំផ្លាញស្រទាប់ អូហ្សូន ដែលបង្កឡើងដោយសារធាតុដែលត្រូវពិនិត្យដូចមានចែងក្នុងឧបសម្ព័ន្ធ A, ឧបសម្ព័ន្ធ B, ឧបសម្ព័ន្ធ C, ឬឧបសម្ព័ន្ធ E ។

(ii) បូកចូលគ្នានូវបរិមាណសារធាតុតាមតួលេខ នៅក្នុងក្រុមសារធាតុដែលត្រូវពិនិត្យនីមួយៗ

b) ការនាំចូលនិងនាំចេញ ដោយអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ក្នុងអនុកថាខ័ណ្ឌ (a) និង ។

c) បរិមាណប្រើប្រាស់ដោយបូកបន្ថែមនូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុ និងការនាំចូល ប៉ុន្តែត្រូវដកចេញនូវកម្រិតប៉ាន់ស្មានលើសារធាតុនាំចេញដូចបានចែង ដោយផ្អែកទៅតាមអនុកថាខ័ណ្ឌ (a) និង (b) ។ ទោះបីយ៉ាងណាក៏ដោយ ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៣ ការនាំសារធាតុដែលត្រូវពិនិត្យទៅកាន់ភាគីមិនមែនជាសមាជិកមិនត្រូវបានដកចេញទេដោយគិតលើកម្រិតប៉ាន់ស្មានលើការប្រើប្រាស់របស់ភាគីនាំចេញ ។

## មាត្រា ៤: ការត្រួតពិនិត្យលើពាណិជ្ជកម្មជាមួយប្រទេសដែលពុំមែនជាភាគី នៃអនុសញ្ញា

**1.** ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩០ ភាគីនីមួយៗនឹងត្រូវហាមឃាត់លើការនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**1 bis.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ B ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**1 ter.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ C ពីប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ ។

**1 qua.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ E ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**1 quin.** ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៤ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុ ដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C ពីប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ ។

**1 sex.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ៣ នៃឧបសម្ព័ន្ធ C ពីប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ ។

**2.** ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៣ ភាគីនីមួយៗ នឹងត្រូវហាមឃាត់លើការនាំចេញសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**2 bis.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ B ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**2 ter.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ C ទៅកាន់ប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ ។

**2 qua.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗនឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ E ទៅកាន់ប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ។

**2 quin.** ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៤ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**2 sex.** ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ៣ នៃឧបសម្ព័ន្ធ C ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**3.** មុនថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩២ ដោយអនុវត្តទៅតាមនីតិវិធីក្នុងមាត្រា ១០ នៃអនុសញ្ញា ភាគីជាសមាជិក ត្រូវរៀបរាប់អោយល្អិតល្អន់នូវបញ្ជីស្តីពីការផលិតសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធិភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគី នៃពិធីសារនេះ។

**3 bis.** អនុលោមទៅតាមនិតិវិធីក្នុងមាត្រា ១០ នៃអនុសញ្ញា ក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗ ត្រូវរៀបរាប់លំអិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ B ។ អនុលោមទៅតាមនីតិវិធីនេះក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធិភាពភាគី ដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគី នៃពិធីសារនេះ ។

**3 ter.** អនុលោមទៅតាមនីតិវិធីក្នុងមាត្រា ១០ នៃអនុសញ្ញា ក្នុងរយៈពេលបីឆ្នាំគិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនីមួយៗនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ ឧបសម្ព័ន្ធ C ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធិភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ ។

**4.** មុនថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៤ ភាគីនឹងត្រូវហាមឃាត់តាមករណីដែលអាចធ្វើបាន ចំពោះការនាំចូលផលិតផលពីប្រទេសដែលពុំមែនជាសមាជិកនៃអនុសញ្ញា ប៉ុន្តែលើកលែងសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A ។
អនុលោមទៅតាមនីតិវិធីក្នុងមាត្រា ១០ នៃអនុសញ្ញា បើសិនការកំណត់អាចធ្វើទៅបាន ភាគីនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុទាំងនេះ ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធិភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគី នៃពិធីសារនេះ។

**4 bis.** ក្នុងអំឡុងពេលប្រាំឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនឹងត្រូវមាន

ការហាមឃាត់តាមករណីដែលអាចធ្វើបាន ចំពោះការនាំចូលផលិតផលពីប្រទេសដែលពុំមែនជាសមាជិកនៃអនុសញ្ញា ប៉ុន្តែលើកលែងសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ B ។ អនុលោមទៅតាមនីតិវិធីក្នុងមាត្រា ១០ នៃអនុសញ្ញា បើសិនការកំណត់អាចធ្វើទៅបាន ភាគីនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុទាំងនេះ ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធិភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធនឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ ។

**4 ter.** ក្នុងអំឡុងពេលប្រាំឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខ័ណ្ឌនេះ ភាគីនឹងត្រូវហាមឃាត់តាមករណីដែលអាចធ្វើបាន ចំពោះការនាំចូលផលិតផលពីប្រទេសដែលពុំមែនជាសមាជិកនៃអនុសញ្ញា ប៉ុន្តែលើកលែងសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ C ។ អនុលោមទៅតាមនីតិវិធីក្នុងមាត្រា ១០ នៃអនុសញ្ញា បើសិនការកំណត់អាចធ្វើទៅបាន ភាគីនឹងត្រូវរៀបរាប់លំអិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុទាំងនេះ ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធិភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគី នៃពិធីសារនេះ។

**5.** ភាគីនីមួយៗ ត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការបញ្ឈប់ការផ្តល់បច្ចេកវិទ្យាសម្រាប់ការផលិត និងការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A, B, C និង C ទៅអោយប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ ។

**6.** ភាគីនីមួយៗ ត្រូវមានការអត់ធ្មត់ចំពោះការផ្តល់ទៅឱ្យប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះជាថវិកាជាជំនួយឬជាកម្មវិធីធានារ៉ាប់រងលើការនាំចេញទៅប្រទេសដែលពុំមែនជាភាគី នៃពិធីសារនេះនូវផលិតផល សម្ភារៈ រោងចក្រ និងបច្ចេកវិទ្យា ដែលសំរួលដល់ការផលិតសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A, B និង C ។

**7.** កថាខ័ណ្ឌ ៥ និង ៦ មិនត្រូវបានអនុវត្តចំពោះផលិតផល សម្ភារៈ រោងចក្រ ឬបច្ចេកវិទ្យា ដែលកែលម្អទៅលើអ្វីដែលមានស្រាប់ ទៅលើការរកឃើញជាថ្មី ការកែច្នៃឡើងវិញ ឬការកាត់បន្ថយសារធាតុដែលត្រូវត្រួតពិនិត្យ ប៉ុន្តែមានទិសដៅបង្កើនការអភិវឌ្ឍន៍ទៅលើសារធាតុដែលត្រូវបានប្រើប្រាស់ដើម្បីជំនួស ឬរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធ A, B និង C ។

**8.** ទោះបីយ៉ាងណាក៏ដោយ យោងទៅតាមការចែងក្នុងកថាខ័ណ្ឌទី ១ រហូតដល់ 4ter. នៃមាត្រានេះ ការនាំចូល ឬនាំចេញនូវសារធាតុដែលត្រូវពិនិត្យទៅកាន់ប្រទេសដែលពុំមែនជាសមាជិក នៃពិធីសារនេះ នឹងអាចត្រូវបានអនុញ្ញាត ប្រសិនបើប្រទេសនេះត្រូវកំណត់ដោយកិច្ចប្រជុំរវាងភាគីជាសមាជិក នៃពិធីសារនេះ ថាបានធ្វើទៅតាមមាត្រា ២ មាត្រា ២A រហូតដល់មាត្រា ២I និងមាត្រានេះហើយបានផ្ញើទិន្នន័យដែលមានសុពលភាពដូចបានបញ្ជាក់ក្នុងមាត្រា ៧ ។

**9.** យោងទៅលើសារធាតុដែលត្រូវពិនិត្យផ្ទាល់ក្នុងមាត្រានេះ ចំពោះពាក្យថា "ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ" គឺសំដៅទៅលើប្រទេសឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលពុំយល់ព្រមទៅនឹងការកំណត់នៃវិធានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពទៅលើសារធាតុដែលត្រូវពិនិត្យនោះ ។

**10.** មុនថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៦ ភាគីជាសមាជិកនឹងត្រូវគិតពិចារណាធ្វើវិសោធនកម្មទៅលើពិធីសារនេះ ដើម្បីពង្រីកវិធានការក្នុងមាត្រានេះអោយមានលក្ខណៈទូលំទូលាយទាក់ទងនឹងការធ្វើពាណិជ្ជកម្មលើសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C និងក្នុងឧបសម្ព័ន្ធ E ចំពោះប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

**<u>មាត្រា 4A :</u> ការពិនិត្យពាណិជ្ជកម្មជាមួយភាគី**

1. កន្លែងណា បន្ទាប់ពីថ្ងៃដែលត្រូវអនុវត្តការលុបបំបាត់សារធាតុត្រួតពិនិត្យ ភាគីមួយមិនមានសមត្ថភាពក៏ដោយ ក៏ត្រូវតែទទួលយកការអនុវត្តតាមគ្រប់ជំហានតាមតម្រូវការរបស់ពិធីសារម៉ុងរ៉េអាល់ ដើម្បីបញ្ឈប់ការផលិត នៃសារធាតុសម្រាប់ប្រើប្រាស់ក្នុងស្រុកជាជាងការយល់ព្រមរបស់ភាគីក្នុងការប្រើប្រាស់ជាចាំបាច់ ។ វាត្រូវបានហាមឃាត់ក្នុងការនាំចេញ សម្រាប់ប្រើប្រាស់ កែច្នៃឡើងវិញ និងកែប្រែបរិមាណសារធាតុក្រៅពីគោលបំណងសម្រាប់បំផ្លាញ ។

2. ក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះបញ្ចូលដោយគ្មានលំអៀងដើម្បីប្រតិបត្តិក្នុងមាត្រា ១១ នៃអនុសញ្ញា និងជានីតិវិធីនៃការមិនអនុវត្តតាមដែលបានបង្កើតឡើងក្រោមមាត្រា ៨ នៃពិធីសារ។

**<u>មាត្រា 4B :</u> អជ្ញាប័ណ្ណ**

1. ភាគីនីមួយៗចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០០ ឬបីខែបន្ទាប់ពីថ្ងៃចូលជាធរមាន នៃមាត្រានេះ ត្រូវបង្កើត និងអនុវត្តប្រព័ន្ធអជ្ញាប័ណ្ណក្នុងការនាំចេញ និងនាំចូលនូវសារធាតុថ្មី ប្រើប្រាស់ កែច្នៃឡើងវិញ និងធ្វើឡើងវិញសារធាតុនៅក្នុងឧបសម្ព័ន្ធ **A, B, C** និង **E** នៅពេលថ្មីៗនេះ។

2. ថ្វីបើកថាខ័ណ្ឌ ១ នៃមាត្រានេះ រាល់ភាគីត្រូវប្រតិបត្តិតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ ដែលសម្រេចមិនសមស្របទៅនឹងការបង្កើត និងអនុវត្តប្រព័ន្ធអាជ្ញាប័ណ្ណសម្រាប់នាំចេញ នាំចូលសារធាតុត្រូវពិនិត្យក្នុងឧបសម្ពន្ធ័ **C** និង **E** ត្រូវបានពន្យាពេលក្នុងសកម្មភាពនេះរហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ និង ថ្ងៃទី ១ ខែមករា ឆ្នាំ២០០២ ដោយឡែកៗពីគ្នា ។

3. គ្រប់ភាគីទាំងអស់ត្រូវតែបង្ហាញ និងធ្វើរបាយការណ៍ទៅលេខាធិការដ្ឋានអំពីការបង្កើត និងដំណើការប្រព័ន្ធអាជ្ញាប័ណ្ណក្រោយពេលនៃការបង្កើតបានបីខែ ។

4. លេខាធិការដ្ឋានត្រូវតែរៀបចំពេលវេលា និងបញ្ចូលទៅក្នុងតារាងភាគីទាំងអស់ដែលបានធ្វើរបាយការណ៍អំពីប្រព័ន្ធអាជ្ញាប័ណ្ណរបស់ពួកគេ និងបញ្ជូនព័ត៏មានទាំងនេះទៅក្រុមប្រឹក្សាអនុវត្តសម្រាប់ពិនិត្យ និងផ្តល់យោបល់សមស្របសម្រាប់ភាគីទាំងនោះ។

**<u>មាត្រា 5 :</u> ស្ថានភាពពិសេស នៃប្រទេសកំពុងអភិវឌ្ឍន៍**

1. ចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់អនុសញ្ញា ឬគិតរហូតមកទល់ថ្ងៃទី ១ ខែមករា ឆ្នាំ១៩៩៩ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានភាគីជាសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ **A** តិចជាង ០.៣ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ នឹងមានសិទ្ធិពន្យាពេលរហូតដល់រយៈពេលដប់ឆ្នាំទៅលើការអនុវត្តន៍តាមវិធានការត្រួតពិនិត្យ ដែលបានកំណត់នៅក្នុងមាត្រាទី **២A** រហូតដល់ **២E** ថាការធ្វើវិសោធនកម្មសំដៅកែតម្រូវ ឬការធ្វើវិសោធនកម្មដើម្បីអនុម័តនៅឯកិច្ចប្រជុំលើកទីពីរក្នុងទីក្រុងឡុង ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩០ នឹងត្រូវដាក់ស្នើទៅភាគីដែលអនុវត្តតាមកថាខ័ណ្ឌនេះ ក្រោយពីបានធ្វើការត្រួតពិនិត្យឡើងវិញដូចមានចែងក្នុងកថាខ័ណ្ឌ ៨ នៃមាត្រានេះ ។

**1 bis.** យោងទៅតាមកថាខ័ណ្ឌ ៨ នៃមាត្រានេះ ភាគីត្រូវទទួលខុសត្រូវពិនិត្យសារឡើងវិញចំពោះការវាយ

តម្លៃបានធ្វើឡើងដោយផ្អែកទៅតាមមាត្រាទី ៦ និងផ្អែកទៅតាមព័ត៌មានពាក់ព័ន្ធ ដែលបានសម្រេចឡើងនៅថ្ងៃទី ១ ខែ មករា ឆ្នាំ១៩៨៦ តាមរយៈនីតិវិធីដែលបានកំណត់ក្នុងកថាខ័ណ្ឌ ៩ នៃមាត្រា ២ :

a) ចំពោះកថាខ័ណ្ឌ ១ ដល់កថាខ័ណ្ឌ ៦ នៃមាត្រា ២F តើឆ្នាំចាប់ផ្តើមត្រូវកំនត់នៅពេលណា ក៏រិតចាប់ផ្តើម គម្រោងពេលត្រួតពិនិត្យ និង កាលបរិច្ឆេទលប់ចោលការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម ១ នៃឧបសម្ព័ន្ធ C ដែលនឹងអនុវត្តចំពោះភាគីក្រោមកថាខ័ណ្ឌ ១ នៃមាត្រានេះ ។

b) ចំពោះមាត្រា ២G តើកាលបរិច្ឆេទដែលត្រូវបដិសេធចំពោះផលិតផល និងការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ C ដែលនឹងត្រូវដាក់ស្នើទៅភាគីដែលអនុវត្តតាមមាត្រានេះ ។

c) ចំពោះមាត្រា ២H តើឆ្នាំចាប់ផ្តើមត្រូវកំណត់នៅពេលណា កម្រិតចាប់ផ្តើមគម្រោងពេលត្រួតពិនិត្យលើការប្រើប្រាស់ និងការផលិតសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ E ដែលនឹងអនុវត្តចំពោះភាគីក្រោម កថាខ័ណ្ឌ ១ នៃមាត្រានេះ ។

2. ទោះបីយ៉ាងណាក៏ដោយ ការអនុវត្តន៍របស់ភាគីតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ មិនត្រូវលើសពីកម្រិតប៉ាន់ស្មានប្រចាំឆ្នាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A ដែលកំណត់ឱ្យតិចជាង ០.៣ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ឬមិនត្រូវលើសកំរិតប៉ាន់ស្មានប្រចាំឆ្នាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ B ដែលកំណត់ឱ្យត្រឹម ០.២ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ។

3. នៅពេលអនុវត្តវិធានការត្រួតពិនិត្យដែលបានកំណត់ក្នុងមាត្រា ២A រហូតដល់ ២E ការអនុវត្តន៍របស់ភាគីតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ នឹងត្រូវបានផ្តល់សិទ្ធិប្រើប្រាស់:

a) ចំពោះសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A តម្លៃមធ្យមនៃកម្រិតប៉ាន់ស្មានប្រចាំឆ្នាំលើការប្រើប្រាស់ក្នុងអំឡុងពេលពីឆ្នាំ ១៩៩៥ ដល់ ១៩៩៧ ឬកម្រិតប៉ាន់ស្មានលើការប្រើប្រាស់ដែលអនុញ្ញាតអោយត្រឹម ០.៣ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំនត់វិធានការត្រួតពិនិត្យ ។

b) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធ B តម្លៃមធ្យមនៃកម្រិតប៉ាន់ស្មានប្រចាំឆ្នាំ លើការប្រើប្រាស់ក្នុងអំឡុងពេលពីឆ្នាំ ១៩៩៨ ដល់ ២០០០ ឬកម្រិតប៉ាន់ស្មានលើការប្រើប្រាស់ដែលអនុញ្ញាតឱ្យត្រឹម ០.២ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំណត់វិធានការត្រួតពិនិត្យ ។

c) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធ A តម្លៃមធ្យមនៃកម្រិតប៉ាន់ស្មានប្រចាំឆ្នាំ លើការផលិតក្នុងអំឡុងពេលពីឆ្នាំ ១៩៩៥ ដល់ ១៩៩៧ ឬកម្រិតប៉ាន់ស្មានលើការផលិតដែលអនុញ្ញាតឱ្យត្រឹម ០.៣ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំណត់វិធានការត្រួតពិនិត្យ ។

d) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធ B តម្លៃមធ្យមនៃកម្រិតប៉ាន់ស្មានប្រចាំឆ្នាំ លើការផលិតក្នុងអំឡុងពេលពីឆ្នាំ ១៩៩៨ ដល់ ២០០០ ឬកម្រិតប៉ាន់ស្មានលើការផលិតដែលអនុញ្ញាតឱ្យត្រឹម ០.២ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំនត់វិធានការត្រួត

ពិនិត្យ ។

**4.** មុនពេលដែលកាតព្វកិច្ចត្រួតពិនិត្យដូចមានចែងក្នុងមាត្រា **២A** រហូតដល់ **២I** អាចអនុវត្តទៅបាន ប្រសិនបើការអនុវត្តន៍របស់ភាគីតាមកថាខ័ណ្ឌ **១** នៃមាត្រានេះ ឃើញថាពុំមានការផ្គត់ផ្គង់គ្រប់គ្រាន់ចំពោះសារធាតុ ដែលត្រូវពិនិត្យគឺភាគីអាចជូនដំណឹងទៅលេខាធិការដ្ឋាន ។ លេខាធិការដ្ឋាន នឹងត្រូវផ្សព្វផ្សាយជាបន្ទាន់ទៅកាន់ភាគីជាសមាជិកនូវឯកសារចម្លងដែលបញ្ជាក់ប្រាប់ជាមុន ពីបញ្ហាដែលនឹងត្រូវលើកយកមកពិចារណានៅក្នុងកិច្ចប្រជុំលើកក្រោយ និងធ្វើសេចក្តីសម្រេចពីសកម្មភាពសមស្របដែលនឹងត្រូវអនុវត្ត ។

**5.** បង្កើនសមត្ថភាពបំពេញកាតព្វកិច្ចលើការអនុវត្តន៍របស់ភាគីតាមកថាខ័ណ្ឌ **១** នៃមាត្រា **៥** ដោយអនុលោមទៅតាមវិធានការត្រួតពិនិត្យដែលបានកំណត់ក្នុងមាត្រា **២A** រហូតដល់ **២E** និងមាត្រា **២I** និងអនុលោមទៅតាមវិធានការត្រួតពិនិត្យផ្សេងទៀតក្នុងមាត្រា **២F** រហូតដល់ **២H** ដែលបានសម្រេចដោយផ្អែកទៅតាមកថាខ័ណ្ឌ **1.bis** នៃមាត្រានេះ រីឯការអនុវត្តន៍ដោយភាគីដដែល នឹងត្រូវពឹងផ្អែកទៅលើប្រសិទ្ធិភាព នៃការអនុវត្តន៍លើកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ ដូចមានចែងដោយមាត្រា **១០** និងមាត្រា **១0A** ដែលទាក់ទងនឹងបន្លាស់ប្តូរផ្នែកបច្ចេកវិទ្យា ។

**6.** ការអនុវត្តន៍របស់ភាគីតាមកថាខ័ណ្ឌ **១** នៃមាត្រា **៥** ពេលខ្លះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាន ចំពោះករណីដែលមានការលំបាកក្នុងការអនុវត្តទោះបីតិចឬច្រើននូវកាតព្វកិច្ចក្នុងមាត្រា **២A** រហូតដល់ **២E** និងមាត្រា **២I** និងក្នុងមាត្រា **២F** រហូតដល់ **២H** ដោយអនុលោមទៅតាមកថាខ័ណ្ឌ **1bis.** នៃមាត្រានេះ ដោយសារតែការអនុវត្តន៍មាត្រា **១០** និង **១0A** នៅមានការខ្វះខាត ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយជាបន្ទាន់ទៅកាន់ភាគីជាសមាជិកនូវឯកសារចម្លងដែលបញ្ជាក់ប្រាប់ជាមុនពីបញ្ហាដែលនឹងត្រូវលើកយកមកពិចារណានៅក្នុងកិច្ចប្រជុំលើកក្រោយលើការទទួលស្គាល់កថាខ័ណ្ឌ **១** នៃមាត្រានេះ និងត្រូវធ្វើសេចក្តីសម្រេចពីសកម្មភាពសមស្របដែលនឹងត្រូវអនុវត្ត ។

**7.** ចន្លោះពេលនៃការជូនពត៏មាននិងការប្រជុំរបស់ភាគី សកម្មភាពសមស្របទៅតាមកថាខ័ណ្ឌ **៦** នៃមាត្រានេះ នឹងត្រូវបានដោះស្រាយ ឬក្នុងរយៈពេលក្រោយមកទៀត បើកិច្ចប្រជុំរបស់ភាគីត្រូវបានដោះស្រាយ នោះនីតិវិធីដែលមិនអនុវត្តទៅតាមមាត្រា **៨** នឹងមិនត្រូវបានយកមកប្រើប្រាស់ទេ ។

**8.** ស្ថានភាពនៃការអនុវត្តន៍របស់ភាគីទៅតាមកថាខ័ណ្ឌ **១** នៃមាត្រានេះ នឹងត្រូវពិនិត្យឡើងវិញដោយកិច្ចប្រជុំរបស់ភាគីរួមមានទាំងការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពលើកិច្ចសហការផ្នែកហិរញ្ញវត្ថុ និងការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាក៏ដូចជាការអនុម័តទៅលើកំណែប្រែ ដែលមានសារៈសំខាន់ចំពោះគម្រោងពេលដែលអាចអនុវត្តដោយភាគីជាសមាជិកទៅលើវិធានការត្រួតពិនិត្យ ។

**8 bis.** យោងតាមសេចក្តីបញ្ចប់នៃការពិនិត្យឡើងវិញក្នុងកថាខ័ណ្ឌ ៨ ខាងលើ:

(a) គោរពតាមឧបសម្ព័ន្ធ **A** នៃសារធាតុត្រូវពិនិត្យ ភាគីមួយប្រតិបត្តិតាមកថាខ័ណ្ឌ **១** នៃមាត្រានេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក និងមានសិទ្ធិពន្យាពេល ១០ ឆ្នាំក្នុងបេ្តជ្ញាចិត្តជាមួយនិងការយល់ព្រមទទួលវិធានការត្រួតពិនិត្យដោយកិច្ចប្រជុំភាគលើកទី ២ នៅទីក្រុងឡុង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩០ និងយោងតាមពិធីសារម៉ុងរ៉េអាល់ មាត្រា **២A** និង **២B** ត្រូវអានដូច្នោះ។

(b) គោរពតាមឧបសម្ព័ន្ធ **B** នៃសារធាតុត្រូវពិនិត្យ ភាគីមួយប្រតិបត្តិតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក និងមានសិទ្ធិពន្យាពេល ១០ ឆ្នាំក្នុងប្តេជ្ញាចិត្តជាមួយនិងការយល់ព្រមទទួលវិធានការត្រួតពិនិត្យដោយកិច្ចប្រជុំភាគលើកទី ២ នៅទីក្រុងឡុង ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩០ និងយោងតាមពិធីសារម៉ុងរ៉េអាល់ មាត្រា **២C** និង **២E** ត្រូវអានដូច្នោះ។

**8 ter.** អនុលោមតាមកថាខ័ណ្ឌ **1 bis** ខាងលើ:

(a) ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៦ និងរយៈពេល ១២ ខែ បន្តបន្ទាប់ភាគីនីមួយៗក្រោមកថាខ័ណ្ឌ ១ នៃមត្រានេះ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ **C** មិនត្រូវលើសកម្រិតប៉ាន់ស្មានលើការប្រើប្រាស់នាឆ្នាំ ២០១៥ ។ ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៦ ភាគីនីមួយៗ ក្រោមកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវប្រតិបត្តិតាមវិធានការត្រួតពិនិត្យដាក់នៅក្នុងកថាខ័ណ្ឌ ៨ នៃមាត្រា **២F** និងដូចមូលដ្ឋានរបស់គេក្នុងការអនុវត្តតាមវិធានការត្រួតពិនិត្យ ហើយត្រូវតែប្រើកម្រិតប៉ាន់ស្មានជាមធ្យមភាគនៃផលិតកម្ម និងការប្រើប្រាស់ក្នុងឆ្នាំ ២០១៥ ។

(b) ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០៤០ និង រយៈពេល ១២ ខែ បន្តបន្ទាប់ភាគីនីមួយៗក្រោមកថាខ័ណ្ឌ ១ នៃមត្រានេះ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់សារធាតុដែល ត្រូវពិនិត្យស្ថិតក្នុងក្រុម ១ នៃឧបសម្ព័ន្ធ **C** មិនត្រូវលើសសូន្យ ។

(c) ភាគីនីមួយៗក្រោមកថាខ័ណ្ឌ ១ នៃមត្រានេះត្រូវប្រតិបត្តិតាមមាត្រា **២G** ។

(d) ស្របតាមសារធាតុត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ **E** :

(i) ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០២ ភាគីដែលប្រតិបត្តិតាមកថាខ័ណ្ឌ ១ នៃមាត្រានេះត្រូវតែយល់ព្រមទទួលនូវវិធានការត្រួតពិនិត្យដែលមានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ២H និងជាមូលដ្ឋានសម្រាប់អនុវត្តតាមវិធានការត្រួតពិនិត្យ ដោយប្រើកម្រិតប៉ាន់ស្មានជាមធ្យមនៃការប្រើប្រាស់ និងការផលិតប្រចាំឆ្នាំរៀងៗខ្លួន ក្នុងកំឡុងឆ្នាំ១៩៩៥ ដល់ ១៩៩៨ ទាំងស្រុង។

(ii) ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ និង រយៈពេល ១២ ខែបន្តបន្ទាប់ភាគីនីមួយៗក្រោមកថាខ័ណ្ឌ ១ នៃមាត្រានេះត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់ និងការផលិតសារធាតុដែលត្រូវពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធ **E** មិនត្រូវលើស ៨០ % កម្រិតប៉ាន់ស្មានលើការប្រើប្រាស់ និងការផលិតប្រចាំឆ្នាំរៀងៗខ្លួន ក្នុងកំឡុងឆ្នាំ ១៩៩៥ ដល់ ១៩៩៨ ទាំងស្រុង។

(iii) ក្នុងរយៈពេល ១២ ខែដំបូង ចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០១៥ និង រយៈពេល ១២ ខែបន្តបន្ទាប់ភាគីនីមួយៗក្រោមកថាខ័ណ្ឌ ១ នៃមត្រានេះត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការប្រើប្រាស់ និងការផលិតសារធាតុដែលត្រូវពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធ **E** មិន

ត្រូវលើសសូន្យ ។ ក្នុងកថាខ័ណ្ឌនេះមានវិសាលភាពចំពោះភាគីក្នុងការអនុញ្ញាតការផលិត ឬប្រើប្រាស់ដែលជាការចាំបាច់ក្នុងការប្រើកិច្ចព្រមព្រៀងរបស់ពួកគេ ។

(iv) ការប៉ាន់ស្មានកំរិតប្រើប្រាស់ និងការផលិតក្រោមកថាខ័ណ្ឌខាងលើនេះ មិនត្រូវរួមបញ្ចូលបរិមាណប្រើប្រាស់សំរាប់បំបាត់កត្តាចង្រៃ និងរៀបចំដឹកជញ្ជូនរបស់ភាគីទេ។

9. ដំណោះស្រាយរបស់ភាគីជាសមាជិក ដោយយោងទៅតាមកថាខ័ណ្ឌ ៤ កថាខ័ណ្ឌ ៦ និង កថាខ័ណ្ឌ ៧ នៃមាត្រានេះ នឹងត្រូវទទួលយកដោយផ្អែកទៅតាមនិតិវិធីដែលបានអនុវត្តចំពោះការធ្វើសេចក្តីសម្រេចចិត្តក្រោមមាត្រា ១០ ដូចគ្នា ។

**មាត្រា ៦: ការវាយតម្លៃ និងការពិនិត្យឡើងវិញចំពោះវិធានការត្រួតពិនិត្យ**

ចាប់ផ្តើមពីឆ្នាំ ១៩៩០ និងយ៉ាងហោចណាស់រៀងរាល់បួនឆ្នាំក្រោយមកទៀត ភាគីជាសមាជិកត្រូវវាយតម្លៃលើវិធានការត្រួតពិនិត្យដែលបង្ខំឱ្យអនុវត្តតាមមាត្រា ២ មាត្រា ២A រហូតដល់ ២I ដោយផ្អែកទៅលើមូលដ្ឋានពត៌មាន វិទ្យាសាស្ត្រ បរិស្ថាន បច្ចេកទេស និងសេដ្ឋកិច្ច ។ យ៉ាងហោចណាស់ រយៈពេលមួយឆ្នាំមុនការវាយតម្លៃនិមួយៗ ភាគីនឹងត្រូវកោះអញ្ជើញក្រុមអ្នកឯកទេសមកប្រជុំកំណត់នូវការរៀបចំសមាសភាពក្រុម និងល័ក្ខខ័ណ្ឌយោង (Term of Reference) ។ ក្នុងអំឡុងពេលមួយឆ្នាំដែលត្រូវបានកោះប្រជុំ ក្រុមអ្នកឯកទេសត្រូវរាយការណ៍ពីការសន្និដ្ឋានរបស់ខ្លួនទៅអោយភាគីជាសមាជិកតាមរយៈលេខាធិការដ្ឋាន ។

**មាត្រា ៧: របាយការណ៍ស្តីពីទិន្នន័យ**

1. ក្នុងអំឡុងពេលបីខែបន្ទាប់ពីបានក្លាយទៅជាភាគីនៃពិធីសារនេះ ភាគីនីមួយៗត្រូវផ្តល់ទៅលេខាធិការដ្ឋាននូវស្ថិតិទិន្នន័យដែលទាក់ទងនឹងការផលិត ការនាំចេញនិងការនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A សម្រាប់ឆ្នាំ១៩៨៦ ឬ ទិន្នន័យប៉ាន់ស្មានដែលអាចកំណត់បាន (ក្នុងខណៈដែលពុំមានទិន្នន័យពិតប្រាកដ)។

2. ភាគីនីមួយៗ ត្រូវផ្តល់ទៅលេខាធិការដ្ឋាននូវស្ថិតិទិន្នន័យដែលទាក់ទងនឹងការផលិត ការនាំចេញឬនាំចូលសារធាតុដែលត្រូវពិនិត្យនីមួយៗ :

ក្នុងឧបសម្ព័ន្ធ B និង C ក្រុម ១, ២ សម្រាប់ឆ្នាំ ១៩៨៩

ក្នុងឧបសម្ព័ន្ធ E សម្រាប់ឆ្នាំ ១៩៩១

ឬទិន្នន័យប៉ាន់ស្មានដែលអាចធ្វើទៅបាន ( ក្នុងខណៈដែលពុំមានទិន្នន័យពិតប្រាកដបញ្ជូនទៅលេខាធិការដ្ឋាន ដោយមិនត្រូវឱ្យយឺតជាងរយៈពេលបីខែបន្ទាប់ពីកាលបរិច្ឆេទដែលសារធាតុក្នុងឧបសម្ព័ន្ធ B ឧបសម្ព័ន្ធ C និង E ត្រូវបានចូលជាធរមាន)។

3. ភាគីនីមួយៗត្រូវផ្តល់នូវស្ថិតិទិន្នន័យដែលទាក់ទងការផលិតប្រចាំឆ្នាំ(ដូចបានកំណត់ក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ១ ) លើសារធាតុត្រូវពិនិត្យនីមួយៗ ដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធ A ឧបសម្ព័ន្ធ B ឧបសម្ព័ន្ធ C និង ឧបសម្ព័ន្ធ E និងត្រូវកំណត់ដាច់ដោយឡែកពីគ្នាចំពោះសារធាតុនីមួយៗ :

--បរិមាណប្រើប្រាស់សម្រាប់ទ្រទ្រង់ដល់ការផលិត

--បរិមាណដែលត្រូវបំផ្លាញចោលដោយបច្ចេកវិទ្យា ដែលអនុម័តដោយភាគីជាសមាជិក

--ការនាំចូល ឬ នាំចេញទៅប្រទេសនីមួយៗដែលជាភាគី ឬ ពុំមែនជាភាគីរបស់ពិធីសារនេះ សម្រាប់ឆ្នាំដែលដែលសេចក្តីចែងចំពោះឧបសម្ព័ន្ធ A ឧបសម្ព័ន្ធ B ឧបសម្ព័ន្ធ C និង ឧបសម្ព័ន្ធ E ត្រូវបានចូលជាធរមាន និងសម្រាប់ឆ្នាំក្រោយៗមកទៀត ។ ទិន្នន័យនឹងត្រូវបញ្ជូនទៅលេខាធិការដ្ឋានឱ្យបានរយៈពេលប្រាំបួនខែនៃឆ្នាំបញ្ចប់ការផ្តល់ពត៌មានពាក់ព័ន្ធ ។ ភាគីនីមួយៗត្រូវផ្តល់ពត៌មានទៅលេខាធិការដ្ឋានស្តីពី នៃសារធាតុត្រូវពិនិត្យដែលមានចែងក្នុងឧបសម្ព័ន្ធ E និងបានប្រើប្រាស់សម្រាប់បំបាត់កត្តាចង្រៃ និងរៀបចំដឹកជញ្ជូនរបស់ភាគី ។

**3.bis.** ភាគីនីមួយៗត្រូវផ្តល់ឱ្យលេខាធិការដ្ឋាននូវទិន្នន័យប្រចាំឆ្នាំដែលធ្វើដាច់ដោយឡែកពីគ្នា ចំពោះការនាំចេញ និងនាំចូលសារធាតុដែលត្រូវពិនិត្យក្នុងក្រុម ២ នៃឧបសម្ព័ន្ធ A និង ក្រុម ១ នៃឧបសម្ព័ន្ធ C និង ឧបសម្ព័ន្ធ E ដែលត្រូវបានកែច្នៃប្រើប្រាស់ឡើងវិញ ។

**4.** សម្រាប់ការអនុវត្តន៍របស់ភាគីតាមសេចក្តីចែងរបស់កថាខ័ណ្ឌ ៨(a) នៃមាត្រា ២ តម្រូវការក្នុងកថាខ័ណ្ឌ ១ កថាខ័ណ្ឌ ២ កថាខ័ណ្ឌ ៣ និង កថាខ័ណ្ឌ 3bis. នៃមាត្រានេះនឹងត្រូវបានបំពេញ ប្រសិនបើអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ផ្តល់នូវទិន្នន័យទាក់ទងស្តីពីការនាំចេញ នាំចូលដែលធ្វើឡើងរវាងអង្គការនេះ និងប្រទេសដែលពុំមែនជាសមាជិករបស់អង្គការនេះ ។

**<u>មាត្រា ៨:</u> ការមិនអនុវត្តន៍តាម**

**Non-compliance**

នៅឯកិច្ចប្រជុំដំបូង ភាគីជាសមាជិក ត្រូវពិចារណា និងអនុម័តលើនីតិវិធី និងយន្តការដែលបានបង្កើតឡើងដើម្បីកំណត់ចំពោះការមិនអនុវត្តន៍តាមសេចក្តីចែងនៃពិធីសារនេះ និងសម្រាប់អនុវត្តទៅលើភាគីទាំងឡាយណាដែលមានភស្តុតាងបញ្ជាក់ថា ពុំបានអនុវត្តតាម ។

**<u>មាត្រា ៩:</u> ការស្រាវជ្រាវ ការអភិវឌ្ឍន៍ ការយល់ដឹងជាសាធារណៈ និងបន្លាស់ប្តូរពត៌មាន**

**1.** ស្របទៅនឹងច្បាប់ បញ្ញាតិនិងស្របទៅតាមច្បាប់ជាតិ ភាគីជាសមាជិកត្រូវសហការ និងគិតគូរជាពិសេសទៅលើតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងគោលដៅជួយឱ្យមានការរីកចំរើនដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរអន្តរជាតិ រួមមានការស្រាវជ្រាវ ការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរពត៌មានទៅលើ:

a) បច្ចេកវិទ្យាសមស្របសម្រាប់កែលម្អនូវអ្វីដែលមានស្រាប់ ការធ្វើឱ្យល្អប្រសើរឡើងវិញ ការកែច្នៃយកមកប្រើប្រាស់ឡើងវិញ ការបំផ្លាញចោលនូវសារធាតុដែលត្រូវពិនិត្យ ឬការកាត់បន្ថយការបញ្ចេញសារធាតុទៅក្នុងបរិយាកាស ។

b) ជំរើសផ្សេងទៀតដែលអនុវត្តចំពោះសារធាតុដែលត្រូវពិនិត្យ ចំពោះផលិតផលផ្ទុកទៅដោយសារធាតុដែលត្រូវពិនិត្យ និងផលិតផលដែលបង្កើតឡើងដោយសារធាតុទាំងនេះ ។

c) តម្លៃ និងអត្ថប្រយោជន៍របស់យុទ្ធសាស្ត្រត្រួតពិនិត្យដែលមានការពាក់ព័ន្ធ ។

2. ភាគីជាសមាជិក ត្រូវសហការដោយផ្ទាល់ឬតាមរយៈស្ថាប័នអន្តរជាតិ ក្នុងគោលដៅជួយបង្កើនការយល់ដឹងរបស់សាធារណជនទៅលើឥទ្ធិពលបរិស្ថាន ដែលបណ្តាលមកពីការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុដែលត្រូវពិនិត្យ ឬសារធាតុដទៃផ្សេងទៀតដែលបំផ្លាញស្រទាប់ អូហ្សូន ។

3. ក្នុងរយៈពេលពីរឆ្នាំនៃការចូលជាធរមានរបស់អនុសញ្ញានេះ និងរយៈពេលពីរឆ្នាំបន្តបន្ទាប់ភាគីជាសមាជិកត្រូវដាក់ស្នើទៅលេខាធិការដ្ឋាន ដើម្បីពិនិត្យលើសកម្មភាពសង្ខេបដោយអនុលោមទៅតាមមាត្រានេះ ។

**មាត្រា ១០ : យន្តការផ្នែកហិរញ្ញវត្ថុ**

1. ភាគីជាសមាជិកត្រូវបង្កើតយន្តការដែលមានគោលដៅផ្តល់កិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស រួមទាំងបន្លាស់ប្តូរផ្នែកបច្ចេកទេសទៅអោយភាគីដទៃ ដែលឋិតនៅក្រោមកថាខ័ណ្ឌ ១ មាត្រា ៥ នៃពិធីសារនេះ ដើម្បីជួយឱ្យការអនុវត្តន៍របស់គេទៅតាមមាត្រា ២ រហូតដល់មាត្រា ២E និងមាត្រា ២I និងវិធានការត្រួតពិនិត្យក្នុង មាត្រា ២F រហូតដល់មាត្រា ២H ដែលអាចសម្រេចបានឡើងដោយផ្អែកទៅលើកថាខ័ណ្ឌ 1 bis. នៃមាត្រា ៥ របស់ពិធីសារនេះ ។ យន្តការ និងការផ្តល់ផ្នែកហិរញ្ញវត្ថុ នឹងត្រូវបញ្ជូនទៅឱ្យភាគីដែលអនុវត្តតាមកថាខ័ណ្ឌនេះ ត្រូវឆ្លើយតបតម្លៃបន្ថែម ដែលបានព្រមព្រៀងដោយភាគីទាំងនោះ ដើម្បីឱ្យវិធានការត្រួតពិនិត្យរបស់ពិធីសារនេះប្រព្រឹត្តទៅមុខបាន ។ តារាងបង្ហាញសន្ទស្សន៍មួយនៃតម្លៃបន្ថែមត្រូវតែសម្រេចដោយការប្រជុំភាគី ។

2. យន្តការដែលបានបង្កើតឡើងក្រោមកថាខ័ណ្ឌ ១ នឹងត្រូវបន្ថែមមូលនិធិពហុភាគី ។ វិធានការនេះ ក៏អាចបញ្ចូលនូវកិច្ចសហប្រតិបត្តិការជាលក្ខណៈពហុភាគី ជាលក្ខណៈតំបន់ និងជាលក្ខណៈទ្វេភាគី ។

3. មូលនិធិពហុភាគីត្រូវ :

a) ឆ្លើយតបទៅនឹងមូលដ្ឋានដ៏សមស្រប នៃជំនួយឬសម្បទាន និងអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលត្រូវសម្រេចដោយភាគីទៅលើតម្លៃបន្ថែមដែលបានព្រមព្រៀងគ្នា ។

b) មុខងាររបស់ផ្នែកមួយ នៃលេខាធិការដ្ឋានដែលទទួលបន្ទុកហិរញ្ញវត្ថុ :

i) ជួយដល់ការអនុវត្តន៍របស់ភាគីដែលប្រព្រឹត្តទៅតាមកថាខ័ណ្ឌ១ នៃមាត្រា ៥ តាមរយៈការសិក្សាជាក់លាក់ក្នុងប្រទេស និងតាមរយៈកិច្ចសហការផ្នែកបច្ចេកទេសសំដៅបង្ហាញនូវតម្រូវការលើកិច្ចសហការ ។

ii) សម្របសម្រួលកិច្ចសហការផ្នែកបច្ចេកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការសហការ ។

iii) ចែកចាយពត៏មាននិងសម្ភារៈដែលពាក់ព័ន្ធ បើកសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពទាក់ទងផ្សេងទៀត ដើម្បីជាផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

iv) សម្របសម្រួល និងត្រួតពិនិត្យទៅលើកិច្ចសហការរវាងពហុភាគី តំបន់ និងទ្វេភាគីដែលបង្កលក្ខណៈល្អប្រសើរដល់ភាគីជាសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ។

c) ការផ្តល់ផ្នែកហិរញ្ញវត្ថុដល់សេវាកម្មរបស់លេខាធិការដ្ឋាននូវមូលនិធិពហុភាគី និងតម្លៃទ្រទ្រង់ការងារ

4. មូលនិធិពហុភាគី ត្រូវប្រតិបត្តិក្រោមសិទ្ធិអំណាចរបស់ភាគី ដែលត្រូវសម្រេចទៅលើនយោបាយរួម ។

5. ភាគីត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិ សំដៅអភិវឌ្ឍន៍ និងត្រួតពិនិត្យទៅលើការអនុវត្តន៍នយោបាយប្រតិបត្តិ

គោលការណ៍នៃនាំនិងការរៀបចំគ្រប់គ្រងរួមមានការចំណាយធនធានសម្រាប់បំពេញកម្មវត្ថុនៃមូលនិធិពហុភាគី ។ គណៈកម្មាធិការប្រតិបត្តិត្រូវបំពេញការងារនិងការទទួលខុសត្រូវ ដូចមានបញ្ជាក់នៅក្នុងល័ក្ខខ័ណ្ឌយោងដែលបានព្រមព្រៀងដោយភាគីដោយមានការសហការ និង ការជួយជ្រោមជ្រែងពីធនាគារអន្តរជាតិដើម្បីការសាងសង់ឡើងវិញនិងការអភិវឌ្ឍន៍ (World Bank) កម្មវិធីបរិស្ថានរបស់សហប្រជាជាតិ (United Nations Environmental Program) កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ (United Nations Development Program) ឬទីភ្នាក់ងារផ្សេងទៀតដែលអាស្រ័យទៅនឹងជំនាញរបស់គេផ្ទាល់ ។ សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវបានជ្រើសរើសតាមការអនុម័តរបស់ភាគីជាសមាជិកដោយផ្អែកទៅតាមគោលការណ៍តុល្យភាពរវាងតំណាងភាគីដែលអនុវត្តតាមកថាខ័ណ្ឌ១ នៃមាត្រា ៥ និងតំណាងអោយភាគីដែលពុំសូវបានអនុវត្តតាម ។

6. តាមរយៈការរួមចំណែកពីភាគីដែលពុំអនុវត្តតាមកថាខ័ណ្ឌ ១ នៃមាត្រា ៥ មូនិធិពហុភាគីនឹងត្រូវផ្តល់ជារូបិយវត្ថុអន្តរជាតិ ឬ ជារូបិយវត្ថុជាតិ ដោយផ្អែកទៅតាមកំរិតប៉ាន់ស្មានរបស់សហប្រជាជាតិ ។ ការរួមចំណែកដោយភាគីដទៃទៀត នឹងត្រូវបានលើកទឹកចិត្ត ។ ក្នុងករណីព្រមព្រៀងដោយសារការសម្រេចពីភាគី កិច្ចសហការជាលក្ខណៈទ្វេភាគី និងជាលក្ខណៈតំបន់អាចកើនឡើង និងស្របជាមួយលក្ខណៈវិនិច្ឆ័យដែលបញ្ជាក់ដោយការសម្រេចរបស់ភាគី នឹងត្រូវចាត់ទុកជាការរួមចំណែកចំពោះមូលនិធិពហុភាគី ដូចដែលបានចែងចំពោះការសហការក្នុងកម្រិតអប្បរមា :

a) អនុលោមទៅតាមសេចក្តីចែងក្នុងពិធីសារនេះ

b) ផ្តល់នូវធនធានបន្ថែម

c) ឆ្លើយតបទៅនឹងតម្លៃបន្ថែមដែលបានព្រមព្រៀង

7. ភាគីត្រូវសម្រេចដោយផ្អែកទៅលើកម្មវិធីថវិការបស់មូលនិធិពហុភាគី សម្រាប់ឆ្នាំសារពើពន្ធនីមួយៗនិងផ្អែកទៅលើភាគរយនៃការចូលរួមរបស់ភាគីនីមួយៗ ។

8. ធនធានរបស់ពហុភាគី នឹងត្រូវចំណាយដែលស្មើនឹងបរិមាណដែលភាគីត្រូវបានទទួល ។

9. សេចក្តីសម្រេចទៅតាមមាត្រានេះដោយភាគីជាសមាជិក អាចនឹងត្រូវអនុម័តទៅតាមមតិទូទៅ ។ ប្រសិនបើកិច្ចប្រឹងប្រែងពុំត្រូវបានឈានទៅរកកិច្ចព្រមព្រៀង នោះសេចក្តីសម្រេចនឹងត្រូវអនុម័តតាមរយៈការបោះឆ្នោតសម្លេងភាគច្រើនគឺពីរភាគបី នៃវត្តមានភាគីចូលរួម ដែលតំណាងអោយសម្លេងភាគច្រើនលើការអនុវត្តន៍ និងមិនអនុវត្តរបស់ភាគីក្រោមកថាខ័ណ្ឌ 1 មាត្រា 5 ។

10. យន្តការផ្នែកហិរញ្ញវត្ថុដែលបានកំណត់ក្នុងមាត្រានេះ មិនត្រូវលំអៀងទៅលើកិច្ចព្រមព្រៀងសំរាប់ពេលអនាគតដែលអាចបង្កើតឡើងដោយអនុលោមទៅតាមបញ្ហាបរិស្ថានទេ ។

**<u>មាត្រា ១០A</u> : បន្លាស់ប្តូរផ្នែកបច្ចេកវិទ្យា**

ភាគីនីមួយៗ ត្រូវអនុវត្តជំណាក់កាលបច្ចេកទេសស្របទៅនឹងកម្មវិធីដែលទ្រទ្រង់ដោយយន្តការហិរញ្ញវត្ថុសំដៅធានាថា:

a) ការជំនួសដោយសុវត្ថិភាពបរិស្ថាននិងបច្ចេកវិទ្យា ត្រូវបានធ្វើការផ្លាស់ប្តូរបំពេះការអនុវត្តន៍របស់ភាគីក្រោមកថាខ័ណ្ឌ ១ មាត្រាទី ៥ ។

b) ការផ្លាស់ប្តូរដោយយោងទៅតាមអនុកថាខ័ណ្ឌ a) ត្រូវបានធ្វើឡើងក្នុងល័ក្ខខ័ណ្ឌល្អសមស្រប ។

**<u>មាត្រា ១១</u>: ជំនួបប្រជុំរបស់ភាគី**

1. ភាគីត្រូវបើកកិច្ចប្រជុំដែលស្ថិតនៅចន្លោះមួយទៀងទាត់ ។ លេខាធិការដ្ឋានត្រូវកោះហៅភាគីជាសមាជិកមកប្រជុំយ៉ាងហោចណាស់ឱ្យបានមុនរយៈមួយឆ្នាំ នៃកាលបរិច្ឆេទដែលពិធីសារនេះបានចូលជាធរមាន ឬដែលសន្និបាតរបស់ភាគីនឹងត្រូវបានគ្រោងធ្វើឡើងនៅឆ្នាំក្រោយក្នុងពេលដដែល ។

2. កិច្ចប្រជុំធម្មតារបស់ភាគី ត្រូវប្រព្រឹត្តឡើងជាបន្តបន្ទាប់ លើកលែងតែមានការសម្រេចពីភាគី និង សន្និបាតរបស់ភាគីអនុញ្ញាត ។ កិច្ចប្រជុំវិសាមញ្ញរបស់ភាគី នឹងត្រូវប្រព្រឹត្តឡើងនៅពេលវេលាមួយទៅតាមតម្រូវការចាំបាច់របស់ភាគីជាសមាជិក ឬតាមរយៈសំណើសុំជាលាយលក្ខណ៍អក្សរដូចបានចែងថាក្នុងអំឡុងពេលប្រាំមួយខែដែលសេចក្តីស្នើសុំត្រូវបានទាក់ទងទៅភាគីជាសមាជិកតាមរយៈលេខាធិការដ្ឋាន នឹងត្រូវមានការគាំទ្រយ៉ាងហោចណាស់មួយភាគបី នៃភាគីជាសមាជិក ។

3. នៅឯកិច្ចប្រជុំលើកទីមួយ ភាគីជាសមាជិកត្រូវ:

a) អនុម័តិដោយនីតិវិធីសម្រេចរួមសម្រាប់កិច្ចប្រជុំរបស់គេ

b) អនុម័តដោយសម្រេចរួមលើផ្នែកហិរញ្ញវត្ថុ ដោយយោងទៅតាមកថាខ័ណ្ឌ ២ មាត្រា ១៣

c) បង្កើតក្រុម និងកំណត់នូវល័ក្ខខ័ណ្ឌយោង ដោយផ្អែកទៅតាមមាត្រា ៦

d) ត្រិះរិះពិចារណា និងអនុម័តទៅលើនីតិវិធី និងយន្តការរបស់ស្ថាប័ន ដូចបានគូសបញ្ជាក់ក្នុងមាត្រា ៨

e) ចាប់ផ្តើមការរៀបចំផែនការ ដោយអនុលោមទៅតាមកថាខ័ណ្ឌ ៣ មាត្រា ១០

4. កិច្ចការឬមុខងាររបស់ភាគីជាសមាជិកនៅក្នុងកិច្ចប្រជុំ:

a) ពិនិត្យឡើងវិញនូវការអនុវត្តន៍ទៅតាមពិធីសារនេះ

b) ធ្វើសេចក្តីសម្រេចលើការកែតម្រូវ ឬកាត់បន្ថយ ដោយយោលទៅតាមកថាខ័ណ្ឌ ៥ មាត្រា ២

c) ធ្វើសេចក្តីសម្រេចលើការបន្ថែម ការដាក់បញ្ចូលឬការដកចេញពីឧបសម្ព័ន្ធនូវសារធាតុឬ វិធានការត្រួតពិនិត្យផ្សេងៗដោយយោលទៅតាមកថាខ័ណ្ឌ ១០ មាត្រា ២ ក្នុងករណីចាំបាច់

d) បង្កើតគោលការណ៍ណែនាំ ឬ នីតិវិធីសម្រាប់ធ្វើរបាយការណ៍ស្តីពីព័ត៌មានដូចបានចែងក្នុងមាត្រា ៧ និងក្នុងកថាខ័ណ្ឌ ៣ មាត្រា ៩

e) ពិនិត្យឡើងវិញទៅលើសំណើសុំជំនួយផ្នែកបច្ចេកទេស ដែលបានដាក់ស្នើសុំដោយយោងទៅតាមអនុកថាខ័ណ្ឌ ៥ មាត្រា ១២

f) ពិនិត្យឡើងវិញទៅលើរបាយការណ៍ ដែលបានរៀបចំដោយលេខាធិការដ្ឋានដោយយោងទៅតាមអនុកថាខ័ណ្ឌ ៥(c) មាត្រា ១២

g) វាយតម្លៃដោយផ្អែកទៅតាមវិធានការត្រួតពិនិត្យក្នុងមាត្រា ៦

h) ត្រិះរិះពិចារណា និងអនុម័តទៅតាមតម្រូវការ ទៅតាមសំណើសុំធ្វើវិសោធនកម្មលើពិធីសារនេះ ឬលើឧបសម្ព័ន្ធមួយចំនួន ឬបង្កើតឧបសម្ព័ន្ធថ្មី

i) ត្រិះរិះពិចារណា និងអនុម័តទៅលើថវិកាសម្រាប់អនុវត្តពិធីសារនេះ

j) ត្រិះរិះពិចារណា និងទទួលខុសត្រូវទៅលើសកម្មភាពបន្ថែមមួយចំនួន ដែលអាចជាតម្រូវការសម្រាប់សម្រេចនូវគោលបំណងរបស់ពិធីសារនេះ ។

**5.** សហប្រជាជាតិ ភ្នាក់ងារឯកទេសនិងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ក៏ដូចជាប្រទេសពុំមែនជាភាគី នៃពិធីសារនេះអាចជាអ្នកអង្កេតការណ៍នៅក្នុងកិច្ចប្រជុំ ។ បុគ្គលទាំងឡាយឬទីភ្នាក់ងារដែលតំណាងឱ្យជាតិ ឬតំណាងឱ្យអន្តរជាតិ តំណាងឱ្យរដ្ឋាភិបាលឬមិនមែនរដ្ឋាភិបាល ដែលទាក់ទងនឹងការងារការពារស្រទាប់ អូហ្សូន ដែលបានជូនដំណឹងទៅលេខាធិការដ្ឋាន អំពីគោលបំណងដែលគេមានវត្តមានក្នុងនាមជាអ្នកអង្កេតការណ៍ និងយ៉ាងហោចណាស់ត្រូវអនុញ្ញាតដោយភាគីជាសមាជិកប្រមាណមួយភាគបី នៃសមាជិកទាំងមូល ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកអង្កេតការណ៍ នឹងត្រូវជាប្រធានបទ ឬជានីតិវិធីដែលត្រូវអនុម័តដោយភាគី ។

**<u>មាត្រា ១២ :</u> លេខាធិការដ្ឋាន**

សម្រាប់ជាគោលបំណង នៃពិធីសារនេះ លេខាធិការដ្ឋានត្រូវ:

a) រៀបចំ និងបំរើកិច្ចប្រជុំរបស់ភាគី ដូចមានចែងក្នុងមាត្រា **១១** ។

b) ទទួល និងរៀបចំទិន្នន័យតាមសំណើរបស់ភាគី ដោយអនុលោមទៅតាមមាត្រា **៧** ។

c) រៀបចំ និងផ្តល់របាយការណ៍យ៉ាងទៀងទាត់ទៅឱ្យភាគីជាសមាជិក ដោយផ្អែកទៅតាមព័ត៌មានដែលទទួលបាន ដូចមានចែងក្នុងមាត្រា **៧** និងមាត្រា **៩** ។

d) ជូនពត៌មានទៅភាគីនូវសំណើសុំជំនួយបច្ចេកទេសដែលបានទទួល ដោយអនុលោមទៅតាមមាត្រា **១០** ឬសម្រួលដល់ការផ្តល់ជំនួបដូចនេះ ។

e) ជំរុញឬលើកទឹកចិត្តឱ្យប្រទេសដែលពុំមែនជាភាគីនៃអនុសញ្ញា ចូលរួមក្នុងកិច្ចប្រជុំរបស់ភាគីក្នុងឋានៈជាអ្នកអង្កេតការណ៍ និងដើរតួរដូចមានចែងក្នុងពិធីសារនេះ ។

f) ផ្តល់យ៉ាងសមស្របនូវពត៌មាននិងសំណើសុំ ដោយយោលទៅតាមអនុកថាខ័ណ្ឌ **៩ c)** និង **d)** ចំពោះអ្នកអង្កេតការណ៍ ។

g) បង្ហាញពីមុខងារ ដើម្បីសម្រេចនូវគោលបំណងពិធីសារនេះ ដែលអាចជាកិច្ចការរបស់ភាគី ។

**<u>មាត្រា ១៣ :</u> ផ្នែកហិរញ្ញវត្ថុ**

**1.** មូលនិធិសម្រាប់អនុវត្តពិធីសារនេះ រួមមានមូលនិធិសម្រាប់ភារកិច្ចរបស់លេខាធិការដ្ឋានដែលពាក់ព័ន្ធ នឹងពិធីសារនេះ នឹងត្រូវផ្តល់ភារកិច្ចផ្តាច់មុខខុសពីការចូលរួមរបស់ភាគីជាសមាជិក ។

**2.** នៅឯកិច្ចប្រជុំលើកដំបូង ភាគីត្រូវអនុម័តដោយបញ្ញាតិរួមលើផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តន៍ពិធីសារនេះ ។

h) ត្រិះរិះពិចារណា និងអនុម័តទៅតាមតម្រូវការ ទៅតាមសំណើសុំធ្វើវិសោធនកម្មលើពិធីសារនេះ ឬលើឧបសម្ព័ន្ធមួយចំនួន ឬបង្កើតឧបសម្ព័ន្ធថ្មី

i) ត្រិះរិះពិចារណា និងអនុម័តទៅលើថវិកាសម្រាប់អនុវត្តពិធីសារនេះ

j) ត្រិះរិះពិចារណា និងទទួលខុសត្រូវទៅលើសកម្មភាពបន្ថែមមួយចំនួន ដែលអាចជាតម្រូវការសម្រាប់សម្រេចនូវគោលបំណងរបស់ពិធីសារនេះ ។

5. សហប្រជាជាតិ ភ្នាក់ងារឯកទេសនិងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ក៏ដូចជាប្រទេសពុំមែនជាភាគី នៃពិធីសារនេះអាចជាអ្នកអង្កេតការណ៍នៅក្នុងកិច្ចប្រជុំ ។ បុគ្គលទាំងឡាយឬទីភ្នាក់ងារដែលតំណាងឱ្យជាតិ ឬតំណាងឱ្យអន្តរជាតិ តំណាងឱ្យរដ្ឋាភិបាលឬមិនមែនរដ្ឋាភិបាល ដែលទាក់ទងនឹងការងារការពារស្រទាប់ អូហ្សូន ដែលបានជូនដំណឹងទៅលេខាធិការដ្ឋាន អំពីគោលបំណងដែលគេមានវត្តមានក្នុងនាមជាអ្នកអង្កេតការណ៍ និងយ៉ាងហោចណាស់ត្រូវអនុញ្ញាតដោយភាគីជាសមាជិកប្រមាណមួយភាគបី នៃសមាជិកទាំងមូល ។ ការអនុញ្ញាត និងការចូលរួមរបស់អ្នកអង្កេតការណ៍នឹងត្រូវជាប្រធានបទ ឬជានីតិវិធីដែលត្រូវអនុម័តដោយភាគី ។

## មាត្រា ១២ : លេខាធិការដ្ឋាន

សម្រាប់ជាគោលបំណង នៃពិធីសារនេះ លេខាធិការដ្ឋានត្រូវ:

a) រៀបចំ និងបំរើកិច្ចប្រជុំរបស់ភាគី ដូចមានចែងក្នុងមាត្រា ១១ ។

b) ទទួល និងរៀបចំទិន្នន័យតាមសំណើរបស់ភាគី ដោយអនុលោមទៅតាមមាត្រា ៧ ។

c) រៀបចំ និងផ្តល់របាយការណ៍យ៉ាងទៀងទាត់ទៅឱ្យភាគីជាសមាជិក ដោយផ្អែកទៅតាមព័ត៌មានដែលទទួលបាន ដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៩ ។

d) ជូនព័ត៌មានទៅភាគីនូវសំណើសុំជំនួយបច្ចេកទេសដែលបានទទួល ដោយអនុលោមទៅតាមមាត្រា ១០ ឬសម្រួលដល់ការផ្តល់ជំនួបដូចនេះ ។

e) ជំរុញឬលើកទឹកចិត្តឱ្យប្រទេសដែលពុំមែនជាភាគីនៃអនុសញ្ញា ចូលរួមក្នុងកិច្ចប្រជុំរបស់ភាគីក្នុងឋានៈជាអ្នកអង្កេតការណ៍ និងដើរតួរដូចមានចែងក្នុងពិធីសារនេះ ។

f) ផ្តល់យ៉ាងសមស្របនូវព័ត៌មាននិងសំណើសុំ ដោយយោលទៅតាមអនុកថាខ័ណ្ឌ ៩ c) និង d) ចំពោះអ្នកអង្កេតការណ៍ ។

g) បង្ហាញពីមុខងារ ដើម្បីសម្រេចនូវគោលបំណងពិធីសារនេះ ដែលអាចជាកិច្ចការរបស់ភាគី ។

## មាត្រា ១៣ : ផ្នែកហិរញ្ញវត្ថុ

1. មូលនិធិសម្រាប់អនុវត្តពិធីសារនេះ រួមមានមូលនិធិសម្រាប់ភារកិច្ចរបស់លេខាធិការដ្ឋានដែលពាក់ព័ន្ធ នឹងពិធីសារនេះ នឹងត្រូវផ្តល់ភារកិច្ចផ្តាច់មុខខុសពីការចូលរួមរបស់ភាគីជាសមាជិក ។

2. នៅឯកិច្ចប្រជុំលើកដំបូង ភាគីត្រូវអនុម័តដោយបញ្ញាតិរួមលើផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តន៍ពិធីសារនេះ ។

**មាត្រា ១៤: ទំនាក់ទំនង នៃពិធីសារទៅអនុសញ្ញា**

សេចក្តីថែ្លងនៃអនុសញ្ញាដែលទាក់ទងពិធីសារនេះ នឹងត្រូវអនុវត្តចំពោះពិធីសារនេះ លើកលែងតែពុំមានចែងក្នុងពិធីសារនេះ ។

**មាត្រា ១៥: ការចុះហត្ថលេខា**

ពិធីសារនេះ នឹងផ្តល់នូវលក្ខណៈសេរីដល់ការចុះហត្ថលេខាដោយរដ្ឋនានា និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងកិច្ចប្រជុំនៅម៉ុងរ៉េអាល់ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៨៧ និងនៅអូតតាវ៉ា ពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ១៩៨៧ រហូតដល់ ថ្ងៃទី ១៦ ខែមករា ឆ្នាំ១៩៨៨ និងនៅទីស្នាក់ការសហប្រជាជាតិ ក្នុងទីក្រុងញ៉ូយកពីថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៨៨ រហូតដល់ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៨៨ ។

**មាត្រា ១៦: ការចូលជាធរមាន**

1. ពិធីសារនេះ នឹងត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែមករា ឆ្នាំ១៩៨៩ ដែលចែងថា យ៉ាងហោចណាស់មានឯកសារច្បាប់ចំនួន ១១ ត្រូវបានអនុម័ត ទទួលស្គាល់ដោយពិធីសារនេះ ដែលបានដាក់ស្នើដោយរដ្ឋនានា និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ច ដែលតំណាងឱ្យយ៉ាងហោចណាស់ពីរភាគបី នៃការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងពិភពលោកនាឆ្នាំ១៩៨៦ ហើយសេចក្តីចែងក្នុងកថាខ័ណ្ឌ ១ មាត្រា **១៧** នៃអនុសញ្ញាត្រូវបានបំពេញ ។ ប្រសិនបើល័ក្ខខ័ណ្ឌ នៃអនុសញ្ញាមិនត្រូវបានបំពេញទៅតាមកាលបរិច្ឆេទកំណត់ ពិធីសារនឹងត្រូវចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីមានការកំណត់កាលបរិច្ឆេទទៅលើល័ក្ខខ័ណ្ឌត្រូវបានបំពេញ ។

2. សម្រាប់គោលបំណងកថាខ័ណ្ឌ ១ ឯកសារច្បាប់ទាំងឡាយដែលបានដាក់ស្នើដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មិនត្រូវបានរាប់បញ្ចូលជាមួយនឹងការដាក់ស្នើរបស់រដ្ឋ ឬប្រទេសដែលស្ថិតក្នុងអង្គការនេះឡើយ ។

3. បន្ទាប់ពីពិធីសារនេះចូលជាធរមាន ប្រទេស ឬរដ្ឋទាំងឡាយ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងត្រូវក្លាយទៅជាភាគីរបស់ពិធីសារនេះក្នុងអំឡុងពេល ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ស្នើនូវឯកសារច្បាប់ដើម្បីសច្ចានុម័ត ទទួលយកអនុម័ត ។

**មាត្រា 17: ការចូលរួមរបស់ភាគីបន្ទាប់ពីពិធីសារចូលជាធរមាន**

ផ្អែកទៅតាមមាត្រា ៥ បន្ទាប់ពីថ្ងៃដែលពិធីសារនេះបានចូលជាធរមានប្រទេស ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលនឹងក្លាយទៅជាភាគីនៃពិធីសារនេះ ត្រូវបំពេញជាបន្ទាន់នូវកាតព្វកិច្ចមួយចំនួនដូចមាន ចែងក្នុងមាត្រា ២ ក៏ដូចជានៅក្នុងមាត្រា ២A រហូតដល់មាត្រា ២I និងមាត្រា ៤ ដែលនឹងត្រូវអនុវត្តក្រោយថ្ងៃដែលគេបានក្លាយទៅជាភាគីដែលជាសមាជិករបស់ពិធីសារក្នុងខណៈដែលពិធីសារនេះបានចូលជាធរមាន ។

**មាត្រា ១៨: ការបម្រុងទុក**

ពុំមានការបម្រុងទុក ដែលបានធ្វើឡើងសម្រាប់ពិធីសារនេះ ។

**<u>មាត្រា ១៩</u> : ការដកចេញ**

ភាគីទាំងឡាយអាចដកខ្លួនចេញពីពិធីសារនេះ ដោយគ្រាន់តែផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់កន្លែងតម្កល់ឯកសារ (លេខាធិការដ្ឋាន)ក្នុងពេលណាក៏បាន បន្ទាប់ពីរយៈពេលបួនឆ្នាំនៃការទទួលខុសត្រូវទៅលើកាតព្វកិច្ច ដូចបានបញ្ជាក់ក្នុងកថាខ័ណ្ឌ ១ មាត្រា ២A ។ ការដកខ្លួនចេញនេះ នឹងមានប្រសិទ្ធិភាពក្រោយពីរយៈពេលមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលលេខាធិការដ្ឋានទទួលនូវពាក្យសុំដកខ្លួនចេញពីពិធីសារនេះ ឬក្រោយថ្ងៃដែលបញ្ជាក់ក្នុងលិខិតសុំដកខ្លួនចេញ ។

**<u>មាត្រា ២០</u> : ឯកសារដើមត្រូវតាមលក្ខណៈច្បាប់**

ឯកសារដើមរបស់ពិធីសារនេះ ដែលសរសេរជាភាសាអារ៉ាប់ ចិន អង់គ្លេស រូស្ស៊ី និង អេស្ប៉ាញ គឺមានតម្លៃស្មើគ្នាតាមលក្ខណៈច្បាប់ នឹងត្រូវតម្កល់នៅឯអគ្គលេខាធិការដ្ឋានសហប្រជាជាតិ ។

## ឧបសម្ព័ន្ធ A

**សារធាតុដែលត្រូវត្រួតពិនិត្យ**

| ក្រុម | សារធាតុ | ការបំផ្លាញស្រទាប់ អូហ្សូន សក្តានុពល* |
|---|---|---|
| ក្រុម ១ | | |
| | $CFCl_3$ (CFC-11) | 1.0 |
| | $CF_2Cl_2$ (CFC-12) | 1.0 |
| | $C_2F_3Cl_3$ (CFC-113) | 0.8 |
| | $C_2F_4Cl_2$ (CFC-114) | 1.0 |
| | $C_2F_5Cl$ (CFC-115) | 0.6 |
| ក្រុម ២ | | |
| | $CF_2BrCl$ (halon-1211) | 3.0 |
| | $CF_3Br$ (halon-1301) | 10.0 |
| | $C_2F_4Br_2$ (halon-2402) | (ត្រូវបានកំណត់) |

* សុពលភាព នៃការបំផ្លាញស្រទាប់ អូហ្សូនត្រូវបានកំណត់ដោយផ្អែកទៅលើការយល់ដឹងស្រាប់ ហើយត្រូវពិនិត្យឡើងវិញទៅតាមដំណាក់កាល ។

## ឧបសម្ព័ន្ធ B

| ក្រុម | សារធាតុ | ការបំផ្លាញស្រទាប់ អូហ្សូន សក្តានុពល* |
|---|---|---|
| ក្រុម ១ | | |
| | $CF_3Cl$ (CFC-13) | 1.0 |
| | $C_2FCl_5$ (CFC-111) | 1.0 |
| | $C_2F_2Cl_4$ (CFC-112) | 1.0 |
| | $C_3FCl_7$ (CFC-211) | 1.0 |
| | $C_3F_2Cl_6$ (CFC-212) | 1.0 |
| | $C_3F_3Cl_5$ (CFC-213) | 1.0 |
| | $C_3F_4Cl_4$ (CFC-214) | 1.0 |
| | $C_3F_5Cl_3$ (CFC-111) | 1.0 |
| | $C_3F_6Cl_2$ (CFC-216) | 1.0 |
| | $C_3F_7Cl$ (CFC-217) | 1.0 |
| ក្រុម ២ | | |
| | $CCl_4$ កាបូនតេត្រាក្លរ៉ាយ | 1.1 |
| ក្រុម ៣ | | |
| | $C_2H_3Cl_3$* 1,1,1-ទ្រីក្លរ៉ូអេតាន (មេទីលក្លរ៉ូហ្វម) | 0.1 |

* រូបមន្តនេះមិនអាស្រ័យទៅនឹង 1,1,2-ទ្រីក្លរ៉ូអេតានទេ ។

# ឧបសម្ព័ន្ធ C

## សារធាតុដែលត្រូវត្រួតពិនិត្យ

| ក្រុម | សារធាតុ | ចំនួនអ៊ីសូមែរ | សក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន* |
|---|---|---|---|
| ក្រុម ១ | | | |
| | $CHFCl_2$ (HCFC-21)** | 1 | 0.04 |
| | $CHF_2Cl$ (HCFC-22)** | 1 | 0.055 |
| | $CH_2FCl$ (HCFC-31) | 1 | 0.02 |
| | $C_2HFCl_4$ (HCFC-121) | 2 | 0.01-0.04 |
| | $C_2HF_2Cl_3$ (HCFC-122) | 3 | 0.02-0.08 |
| | $C_2HF_3Cl_2$ (HCFC-123) | 3 | 0.02-0.06 |
| | $CHCl_2CF_3$ (HCFC-123)** | - | 0.02 |
| | $C_2HF_4Cl$ (HCFC-124) | 2 | 0.02-0.04 |
| | $CHFClCF_3$ (HCFC-124)** | - | 0.022 |
| | $C_2H_2FCl_3$ (HCFC-131) | 3 | 0.007-0.05 |
| | $C_2H_2F_2Cl_2$ (HCFC-132) | 4 | 0.008-0.05 |
| | $C_2H_2F_3Cl$ (HCFC-133) | 3 | 0.02-0.06 |
| | $C_2H_3FCl_2$ (HCFC-141) | 3 | 0.005-0.07 |
| | $CH_3CFCl_2$ (HCFC-141b)** | - | 0.11 |
| | $C_2H_3F_2Cl$ (HCFC-142) | 3 | 0.008-0.07 |
| | $CH_3CF_2Cl$ (HCFC-142b)** | - | 0.065 |
| | $C_2H_4FCl$ (HCFC-151) | 2 | 0.003-0.005 |
| | $C_3HFCl_6$ (HCFC-221) | 5 | 0.015-0.07 |
| | $C_3HF_2Cl_5$ (HCFC-222) | 9 | 0.01-0.09 |
| | $C_3HF_3Cl_4$ (HCFC-223) | 12 | 0.01-0.09 |
| | $C_3HF_4Cl_3$ (HCFC-224) | 12 | 0.01-0.08 |
| | $C_3HF_5Cl_2$ (HCFC-225) | 9 | 0.02-0.07 |
| | $CF_3CF_2CHCl_2$ (HCFC-225ca)** | - | 0.025 |
| | $CF_2ClCF_2CHClF$ (HCFC-225cb)** | - | 0.033 |
| | $C_3HF_6Cl$ (HCFC-226) | 5 | 0.02-0.10 |
| | $C_3H_2FCl_5$ (HCFC-231) | 9 | 0.05-0.09 |
| | $C_3H_2F_2Cl_4$ (HCFC-232) | 16 | 0.008-0.10 |
| | $C_3H_2F_3Cl_3$ (HCFC-233) | 18 | 0.007-0.23 |
| | $C_3H_2F_4Cl_2$ (HCFC-234) | 16 | 0.01-0.28 |
| | $C_3H_2F_5Cl$ (HCFC-235) | 9 | 0.03-0.52 |
| | $C_3H_3FCl_4$ (HCFC-241) | 12 | 0.004-0.09 |
| | $C_3H_3F_2Cl_3$ (HCFC-242) | 18 | 0.005-0.13 |
| | $C_3H_3F_3Cl_2$ (HCFC-243) | 18 | 0.007-0.12 |
| | $C_3H_3F_4Cl$ (HCFC-244) | 12 | 0.009-0.14 |
| | $C_3H_4FCl_3$ (HCFC-251) | 12 | 0.001-0.01 |
| | $C_3H_4F_2Cl_2$ (HCFC-252) | 16 | 0.005-0.04 |
| | $C_3H_4F_3Cl$ (HCFC-253) | 12 | 0.003-0.03 |
| | $C_3H_5FCl_2$ (HCFC-261) | 9 | 0.002-0.02 |
| | $C_3H_5F_2Cl$ (HCFC-262) | 9 | 0.002-0.02 |
| | $C_3H_6FCl$ (HCFC-271) | 5 | 0.001-0.03 |

| | | | |
|---|---|---|---|
| ក្រុម ២ | | | |
| | $CHFBr$ | 1 | 1.00 |
| | $CHF_2Br$ (HBFC-22B1) | 1 | 0.74 |
| | $CH_2FBr$ | 1 | 0.73 |
| | $C_2HFBr_4$ | 2 | 0.3-0.8 |
| | $C_2HF_2Br_3$ | 3 | 0.5-1.8 |
| | $C_2HF_3Br_2$ | 3 | 0.4-1.6 |
| | $C_2HF_4Br$ | 2 | 0.7-1.2 |
| | $C_2H_2FBr_3$ | 3 | 0.1-1.1 |
| | $C_2H_2F_2Br_2$ | 4 | 0.2-1.5 |
| | $C_2H_2F_3Br$ | 3 | 0.7-1.6 |
| | $C_2H_3FBr_2$ | 3 | 0.1-1.7 |
| | $C_2H_3F_2Br$ | 3 | 0.2-1.1 |
| | $C_2H_4FBr$ | 2 | 0.07-0.1 |
| | $C_3HFBr_6$ | 5 | 0.3-1.5 |
| | $C_3HF_2Br_5$ | 9 | 0.2-1.9 |
| | $C_3HF_3Br_4$ | 12 | 0.3-1.8 |
| | $C_3HF_4Br_3$ | 12 | 0.5-2.2 |
| | $C_3HF_5Br_2$ | 9 | 0.9-2.0 |
| | $C_3HF_6Br$ | 5 | 0.7-3.3 |
| | $C_3H_2FBr_5$ | 9 | 0.1-1.9 |
| | $C_3H_2F_2Br_4$ | 16 | 0.2-2.1 |
| | $C_3H_2F3Br_3$ | 18 | 0.2-5.6 |
| | $C_3H_2F_4Br_2$ | 16 | 0.3-7.5 |
| | $C_3H_2F_5Br$ | 8 | 0.9-14 |
| | $C_3H_3FBr_4$ | 12 | 0.08-1.9 |
| | $C_3H_3F_2Br_3$ | 18 | 0.1-3.1 |
| | $C_3H_3F_3Br_2$ | 18 | 0.1-2.5 |
| | $C_3H_3F_4Br$ | 12 | 0.3-4.4 |
| | $C_3H_4FBr_3$ | 12 | 0.03-0.3 |
| | $C_3H_4F_2Br_2$ | 16 | 0.1-1.0 |
| | $C_3H_4F_3Br$ | 12 | 0.07-0.8 |
| | $C_3H_5FBr_2$ | 9 | 0.04-0.4 |
| | $C_3H_5F_2Br$ | 9 | 0.07-0.8 |
| | $C_3H_6FBr$ | 5 | 0.02-0.7 |
| ក្រុម ៣ | | | |
| | $CH_2BrCl$ (bromochloromethane) | 1 | 0.12 |

* ចន្លោះតម្លៃរបស់សក្តានុពលនៃការបំផ្លាញស្រទាប់ អូហ្សូនត្រូវបានបង្ហាញ ដែលក្នុងនោះតម្លៃខ្ពស់បំផុតត្រូវបានប្រើសម្រាប់គោលបំណងនៃពិធីសារនេះ ។ សក្តានុពលភាពនៃការបំផ្លាញស្រទាប់ អូហ្សូន បានចុះបញ្ជីជាតម្លៃទោល ដែលបានកំណត់តាមការគណនា ដោយផ្អែកទៅតាមវិធានការរបស់ទីពិសោធន៍ ។ តម្លៃដែលបានចុះបញ្ជី ដោយស្ថិតនៅចន្លោះតម្លៃកំណត់ គឺផ្អែកទៅតាមតម្លៃប៉ាន់ស្មាននិងពុំសូវពិតប្រាកដ ។ តម្លៃដែល

ស្ថិតនៅចន្លោះកំណត់មានការទាក់ទងទៅនឹងក្រុមអ៊ីសូមែរ ។ តម្លៃខ្ពស់ជាការវាយតម្លៃទៅលើសក្ដានុពលនៃការបំផ្លាញស្រទាប់ អូហ្សូនរបស់អ៊ីសូមែរដែលមានសក្ដានុពលខ្ពស់បំផុតទៅលើការបំផ្លាញស្រទាប់ អូហ្សូន រីឯតម្លៃទាប គឺជាការប៉ាន់ប្រមាណលើសក្ដានុពលនៃការបំផ្លាញស្រទាប់ អូហ្សូន របស់អ៊ីសូមែរ ដែលមានតម្លៃសក្ដានុពល នៃការបំផ្លាញស្រទាប់ អូហ្សូន ក្នុងកម្រិតទាបបំផុត ។

** បញ្ជាក់ទៅលើសារធាតុដែលអាចធ្វើពាណិជ្ជបាន រួមជាមួយនឹងតម្លៃសក្ដានុពលនៃការបំផ្លាញស្រទាប់ អូហ្សូន ដែលបានចុះបញ្ជីប្រើប្រាស់សម្រាប់គោលបំណងរបស់ពិធីសារ ។

## 2. ឧបសម្ព័ន្ធ D

បញ្ជីឈ្មោះសារធាតុ** ដែលមានសារធាតុដែលត្រូវពិនិត្យ ដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ A

| ផលិតផល | លេខកូត |
|---|---|
| ១. ម៉ាស៊ីនត្រជាក់នៅក្នុងរថយន្តដឹកទំនិញនិងរថយន្តផ្សេងៗ (មាននៅក្នុងយានយន្តឬអត់) | .................. |
| ២. សម្ភារៈម៉ាស៊ីនបឺតកំដៅ ម៉ាស៊ីនត្រជាក់ ទូទឹកកកដែលប្រើប្រាស់ក្នុងលំនៅដ្ឋាន និងសម្រាប់ប្រកបអាជីវកម្មផ្សេងៗ*** ។ល។ | .................. |
| - ទូទឹកកក | .................. |
| - ទូភ្លាសេ្ស | .................. |
| - ម៉ាស៊ីនសម្ងួត | .................. |
| - ម៉ាស៊ីនដើម្បីឱ្យទឹកត្រជាក់ | .................. |
| - ម៉ាស៊ីនផលិតទឹកកក | .................. |
| - ឧបករណ៍បឺតកំដៅនិងឧបករណ៍ម៉ាស៊ីនត្រជាក់ | .................. |
| ៣. ផលិតផល Aerosols លើកលែងតែផលិតផលឱសថមានលក្ខណៈ Aerosols | .................. |
| ៤. ឧបករណ៍ចល័តពន្លត់អគ្គិភ័យ | .................. |
| ៥. សារធាតុអ៊ីសូឡង់ដែលប្រើប្រាស់សម្រាប់ការពារបំពង់ទឹក និងសារធាតុផ្សេងៗ | .................. |
| ៦. សារធាតុមុននឹងក្លាយទៅជាសារធាតុប៉ូលីមែ | .................. |

* ឧបសម្ព័ន្ធនេះត្រូវបានអនុម័តដោយកិច្ចប្រជុំលើកទីបីរបស់ភាគីជាសមាជិក នៅ ណាយរ៉ូប៊ី (Nairobi) កាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ១៩៩១ ទៅតាមតម្រូវការរបស់កថាខ័ណ្ឌ ៣ នៃមាត្រា ៤ របស់ពិធីសារ ។

** នៅពេលផលិតផលដឹកជញ្ជូនដែលតម្រូវទៅតាមសេចក្តីត្រូវការរបស់បុគ្គលនិងការប្រើប្រាស់ក្នុងលំនៅដ្ឋាន ឬស្ថិតក្នុងស្ថានភាពក្រៅពីការធ្វើជំនួញ ដែលជាធម្មតាគឺត្រូវបានស្ថាប័នគយលើកលែងការយកពន្ធ ។

*** នៅពេលដែលមានសារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធ A ដូចជាផលិតផលសារធាតុធ្វើអោយត្រជាក់ឬសារធាតុអ៊ីសូឡង់ ។

## ឧបសម្ព័ន្ធ E

| ក្រុម | សារធាតុ | សក្តានុពលនៃការបំផ្លាញស្រទាប់ អូហ្សូន |
|---|---|---|
| ក្រុម ១ | $CH_3Br$ មេទីលប្រូម៉ាយ | 0.6 |